សិក្សាពិចារណា

# ប្រវត្តិ អក្សរសាស្ត្រខ្មែរ



CA30

# ប្រវត្តិ
# អក្សរសាស្ត្រខ្មែរ

ស្រង់ចេញពីកាសែតសាមគ្គី

បោះផ្សាយលើកទី ៤

មិនា ១៩៦១

រក្សាសិទ្ធិ

# អារម្ភកថា

នៅក្រោមនឹមដែកចក្រពត្រអាណានិគមនិយមជិត ១០០ ឆ្នាំ គន្លងទៅហើយ ប្រជាជនយើងស្រីប្រុសត្រូវឃ្លាតចេញឆ្ងាយពីវប្បធម៌ជាតិ ពីប្រវត្តិសាស្ត្រជាតិ ត្រូវអាណានិគមនិយមបារាំងបង្ខំឲ្យរៀនភាសាគេ ឲ្យទទួលប្រើអក្សរគេជាផ្លូវការ ឲ្យក្រេបជញ្ជក់នូវវប្បធម៌ចក្រពត្រនិយមពុករលួយ ៗ ដូច្នេះហើយ បានជាយើងច្រើនមានគុណវិបត្តិអវណ្ណាគអណ្តែតវិលតាមគេមាក់ងាយភ្លេចកេរ្តិ៍ដំណែលស្នាដៃ ប្រជាជនខ្មែរយើងមានសិល្បអក្សរសាស្ត្រជាដើម ។

ចាប់តាំងពីលេខមួយរៀងរហូតមកទល់នឹងថ្ងៃឈប់កា-សែត «សាមគ្គី» បានខិតខំញែកដោះស្រាយបញ្ហានយោបាយ សេដ្ឋកិច្ច, សង្គមកិច្ច, វប្បធម៌, កីឡា ជូនបងប្អូនពិចារណា ៗ

ដើម្បីជាប្រយោជន៍ដល់បងប្អូនរួមជាតិ គ្រប់ជាន់ថ្នាក់ ដើម្បីជួយបង្កើនសៀវភៅសិក្សាពិចារណា, យើងខ្ញុំសូម

ប្រមូលអត្ថបទ «អក្សរសាស្ត្រខ្មែរ» បង្កើតជាសៀវភៅ ។

សូមបងប្អូនខ្មែរជាតិជួយពិនិត្យពិចារណានូវឯកសារនេះ ។

មិនា ១៩៥៦

អតីតភ្នាក់ងារកាសែតសាមគ្គី

ទឹម–សំ ឌិ

# ប្រវត្តិកំណើតអក្សរសាស្ត្រ

មនុស្សលោកតាំងពីដាន់ដើមប្រកបរបររកស៊ីផ្អែកនៅលើធម្មជាតិហើយប្រើកម្លាំងផ្ទាល់មានបរបាញ់ នេសាទនិងដាំដំណាំបន្តិចបន្តួចគ្រប់គ្រាន់តែចិញ្ចឹមគ្រួសារខ្លួន, កុលសម្ព័ន្ធខ្លួនប៉ុណ្ណោះ ។ សង្គមភាពក្នុងសង្គមជំនាន់នោះមានតិចតួចស្តួចស្តើងជាអនេក ។ ម្លោះហើយ ការទាក់ទងរវាងក្រុមនិងរវាងកុលសម្ព័ន្ធក៏មិនសូវជាស្មុគស្មាញប៉ុន្មានដែរ គ្រាន់តែនិយាយនឹងសំដែងគ្នាទៅវិញទៅមកក៏ជាការស្រេច ។ ក៏ប៉ុន្តែដល់កុលសម្ព័ន្ធដុះដាលរីកធំឡើង, សង្គមភាពក្នុងសង្គមក៏ចែកសាយជាច្រើនសណ្ឋានឡើង ឯការទាក់ទងរវាងមនុស្សនិងមនុស្ស រវាងក្រុមនិងក្រុមក៏រឹតតែមានសភាពធំទូលាយឡើង

ម្ល៉ោះហើយការនិយាយដោយសំដីសុទ្ធ ៗ ឃើញថាមិនគ្រប់គ្រាន់នឹងបំពេញសកម្មភាពក្នុងសង្គមបាន ។

ហេតុដូច្នេះ មនុស្សងាកទៅរកគំនូសនិងសញ្ញាផ្សេង ៗ ដើម្បីសំគាល់របស់របរសព្វសារពើ ដើម្បីកត់ចំណាំទុកនូវរបៀបប្រើប្រាស់គ្រឿងផលិតកម្មផ្សេង ៗ ដើម្បីទុកដំណែលឲ្យកូនចៅរបស់ខ្លួននូវឧត្តមគតិ,លទ្ធិគ្រប់ចំពូក ។ល។ តមកទៀតជីវភាពមនុស្សកាន់តែសាំញ៉ាំឡើង ៗ សង្គមកាន់តែមានវឌ្ឍនធម៌ចំរើនលឿនទៅមុខជាអនេក ធ្វើឲ្យគំនូសសញ្ញាទាំងឡាយ ដែលពីដើមគ្រាន់តែជាបុព្វហេតុមធ្យោបាយ ឥ-ឡូវប្រែក្លាយទៅជាអក្សរ រួចក៏មានផ្តុំជាអក្សរសាស្ត្រដូចយើងសព្វថ្ងៃ ។

អក្សរសាស្ត្រជាមែកធាងនៃវប្បធម៌ ៗ ដូចសិល្បក្តី ប៉ុន្តែទាំងពួង អក្សរសាស្ត្រអាចឲ្យយើងឆ្លុះមើលឃើញការរស់នៅក្នុងសង្គមមនុស្សក្នុងរយៈណាមួយ ។

អក្សរសាស្ត្រមិនមានចរិតដូចគ្នាទាំងអស់ទេ គឺជាប់នឹង

សង្គម ៗដូច្នេះ អក្សរសាស្ត្រត្រូវប្រែប្រួលទៅតាមការវិវត្តន៍សង្គមនៃមនុស្សជាដាច់ខាត ។

សង្គមសក្តិភូមិ មានអក្សរសាស្ត្ររបស់គេៗអត្ថរសអក្សរសាស្ត្រនោះ ច្រើនផ្អែកទៅលើសាសនា ច្រើនផ្អែកលើបុគ្គលមួយរូបៗដែលគេច្រើនលើកតម្កើង ជាតំណាង «អាទិទេព» តំណាង «ព្រះឥន្ទ្រ» តំណាង «ព្រះម្ចាស់សួគ៌» តំណាង «ព្រះពោធិសត្វ» ឬ «ព្រះពុទ្ធ» យកកំណើតក៏មាន ។ គេច្រើនរាប់ថាបុគ្គលនោះគឺជាពូជខ្ពស់បុះពី «ឋានលើ» មកយកកំណើត ហើយត្រូវមានឥទ្ធិពលបង្ក្រាបជិះជាន់គេបានតាមចិត្ត បាញ់សម្លាប់បានទាំងអស់ គ្មានច្បាប់ឯណាធំជាងបុគ្គលមួយរូបនោះទេ ។ គេនិយាយដូច្នេះ ដើម្បីគេបោកប្រាសប្រជាជនឲ្យសុខចិត្តគោរពកោតខ្លាចចុះចូលខ្លួនដូចសត្វតិរច្ឆាន ។

អក្សរសាស្ត្រសង្គមមូលធននិយម ច្រើនបង្អិលប្រជាជនឲ្យអណ្តែតអណ្តូងយល់ឃើញថា «លោកតាប្រាក់ធំជាងគេ» ។ គេបង្កើតបណ្តុះគំនិតដូច្នេះ ព្រោះគេឲ្យប្រជាជនភ្លាត់តាមយុន

សុខចិត្តឲ្យគេប្រើរៀងរហូតទៅ ហើយឲ្យយល់ថាមានតែនាយទុនទេ ដែលជាម្ចាស់ធនធានក្នុងសង្គមទាំងអស់ ។

អក្សរសាស្ត្រសង្គមនិយម មានចរិតប្រជាជាតិប្រជាជនទីធំ វិទ្យាសាស្ត្របានន័យថា ដឹកនាំប្រជាជនឲ្យស្គាល់កម្លាំងរបស់ខ្លួនឲ្យលះបោលនូវជំនឿគ្មានសមហេតុផល ។ អក្សរសាស្ត្រសង្គមនិយមផ្អែកទៅលើវិទ្យាសាស្ត្រ ដែលអាចបង្ហាញមនុស្សឲ្យឃើញការពិតជាក់ស្តែងនឹងអាចជួយសម្រាលកម្លាំងមនុស្សក្នុងការបង្កើតផលិតផល ។ល។

ដូចយើងបានឃើញខ្លះហើយ នៅសង្គមសក្តិភូមិ ឬទុននិយមមានមនុស្សជិះជាន់មនុស្ស ដែលជាមូលហេតុធំឲ្យមានវណ្ណៈក្នុងសង្គមនោះប្រឆាំងគ្នា ។ នៅសង្គមសក្តិភូមិ ការទំនាស់វណ្ណៈ មានកើតឡើងដោយពួកសក្តិភូមិជិះជាន់ពួកកសិករ ដែលទ្រាំមិនបានក៏ប្រឆាំងតបវិញ ។ នៅសង្គមទុននិយម ការទំនាស់វណ្ណៈកើតឡើងដោយពួកនាយទុន (គ្នាតិច) ជិះជាន់សង្កត់សង្កិនពួកអធនមានកម្មករ កសិករ

(គ្នាច្រើន)ៗ ការចំនាស់វណ្ណៈនេះហើយ ដែលជាមូលហេតុមួយធំ ជម្រុលសង្គមមនុស្សអន់ថយឲ្យឡើងទៅសង្គមជឿនលឿន ដូចជាមានការបដិវត្តន៍ប្រជាជនកសិករវាយរំលាយរបបសក្តិភូមិ ហើយទាំងកម្មករកសិករវាយរំលាយរបបមូលធននិយមចោល ហើយតាំងរបបសង្គមនិយមថ្មីៗ ការចំនាស់វណ្ណៈនេះ បានបញ្ចាំងក្នុងអក្សរសាស្ត្រៗ គេអាចឃើញក្នុងសង្គមមូលធននិយមនិងសង្គមសក្តិភូមិ មានអក្សរសាស្ត្រពីរយ៉ាង ប្រឆាំងគ្នាបំរើវណ្ណៈរៀងខ្លួន អក្សរសាស្ត្រជឿនលឿនបដិវត្តន៍ នឹងអក្សរសាស្ត្របដិកិរិយា ៗ

**អក្សរសាស្ត្រជឿនលឿនបដិវត្តន៍**– អក្សរសាស្ត្រនេះ ច្រើនកើតឡើងសម្រាប់ប្រជាជនហើយមិនបានចងក្រងជាសៀវភៅទេ ច្រើនតែនិយាយគ្នាពីមាត់មួយទៅមាត់មួយៗ រឿងនេះកើតឡើងដុះពីទ្រូងប្រជាជន ហើយនិយាយចេញពីមាត់មួយទៅមាត់មួយរកម្ចាស់ដើមមិនឃើញឡើយៗ យ៉ាង

ទៀតអ្នកកាន់អំណាចនៅសម័យនោះ មិនបានយកចិត្តទុកដាក់ទំនឹងតារ ឬបោះពុម្ពទុកជាសាស្ត្រាឲ្យប្រជាជនរៀន ដឹងឮគ្រប់គ្នាទេ ផ្ទុយទៅវិញ គេរកតែបំបាត់ចោលឲ្យសូន្យឈឹងៗ

អក្សរសាស្ត្របដិកិរិយា— អក្សរសាស្ត្រនេះបំរើវណ្ណៈខ្លាំងពួកជិះជាន់គេក្នុងសង្គមមនុស្សជិះជាន់មនុស្ស ៗ វណ្ណៈកាន់អំណាចសុទ្ធតែមានគ្រោងការណ៍ បណ្ដុះឲ្យពួកគេបំរើខ្លួន តែងចងជាច្បាប់ ជាសៀវភៅសាស្ត្រាមានមុខងារធំតម្កើងក្រុមខ្លួន ៗ គេបោះពុម្ព គេចារ គេដាក់កម្មវិធីឲ្យប្រជាជនរៀនទន្ទេញប្រតិបត្តិតាម ៗ គេបញ្ចូលទៅក្នុងក្បាលប្រជាជនតែអក្សរសាស្ត្រ បំរើវណ្ណៈខ្លាំងពួកជិះជាន់គេ តាំងពីកុមាររហូតដល់ចាស់ស្លាប់ ៗ ក្នុងសាលារៀនក្នុងវត្ត គេយកតែរឿងអក្សរសាស្ត្រនៃវណ្ណៈ នៃក្រុមគេទៅបញ្ចូលទៅផ្សាយ ៗ

ចំពោះអក្សរសាស្ត្រខ្មែរ ដែលយើងត្រូវរកញែករៀននៅខាងមុខនេះ យើងនឹងពិនិត្យតាមរបៀបខាងលើ ដែល

យើងបានឆ្លុះមើលអក្សរសាស្ត្រទូទៅ ក្នុងលំនាំដើមនេះ ។ យើងសូមបងប្អូនអ្នកអានសៀវភៅយើង ជួយជ្រោមជ្រែង ទិទៀនអត្ថបទយើងនឹងកែតម្រូវឲ្យផង ក្នុងការពិនិត្យរៀនអក្សរសាស្ត្រខ្មែរនេះ ។

—oo—

# អក្សរសាស្ត្រខ្មែរ

យើងបាននិយាយក្នុងលំនាំដើមថា អក្សរសាស្ត្រប្រែប្រួលជាប់ទៅតាមការវិវត្តន៍សង្គមជានិច្ច ។ ហេតុនេះ ដើម្បីពិនិត្យមើលឲ្យស្គាល់ច្បាស់ តើអក្សរសាស្ត្រយើងមានប្រវត្តិដូចម្ដេចខ្លះ យើងត្រូវស្គាល់ប្រវត្តិសង្គមយើងជាមុនសិន ។

កាលឆ្នាំ ១៨៦៣ ពេលដែលបារាំងដាក់ប្រទេសយើងជាប្រទេសចំណុះ សង្គមខ្មែរយើងជាសង្គមសក្តិភូមិមានកំផែលទាសភាព(ដូចមានទិញលក់មនុស្សជាដើម) និងកំផែលកុលសម្ពន្ធ (រស់នៅជាគ្រួសារដោយត្រកូលដូចគ្នា) ។ របបគ្រប់គ្រងនឹងសម្បូរណាញាសិទ្ធិរាជបានន័យថា „ព្រះរាជាទទួលអំណាចគ្រប់ចំពូកពីទេវស្ថាន„ ។ ប្រជាជនគ្មានសិទ្ធិសេរីភាព ។

សង្គមខ្មែរយើងជាន់នោះ មានចែកជាវណ្ណៈខត្តិយៈ,ព្រាហ្មណ៍ ពូជព្រៃងារ, ពូជអ្នកងារ ដូចមានពន្យល់ក្នុងវេទានុក្រមជាកំស្តាំងស្រាប ។ ដូច្នេះ គេអាចសង្កេតឃើញក្នុងសង្គមខ្មែរមានមនុស្សពីរក្រុមធំ ៗ បណ្ដាអ្នកធំមានអំណាចបង្កើតទំនៀមទម្លាប់ច្បាប់សម្រាប់ក្រុមខ្លួន ហើយដាក់បង្អាប់ទៅឲ្យប្រជាជនធ្វើតាមគោរពទំនៀមទម្លាប់ទាំងនោះ ។

ក្រោយឆ្នាំ ១៨៦៣ បក្រពត្របារាំង បានចូលដាក់ប្រទេសយើងជាចំណុះ ។ គេផ្អែកទៅលើរបបសក្តិភូមិ ។ គេមកជិះជាន់ប្រជាជនយើងគ្រប់ជាន់ថ្នាក់ ។ សង្គមខ្មែរយើងមិនបានប្រែប្រួលអ្វីប៉ុន្មានទេ ពិតមែនតែមានច្បាប់ខ្លះបំបាត់វណ្ណៈអ្នកងារ ។ ក្នុងរយៈចំណុះបារាំងរៀងរហូតមកដល់ឆ្នាំ១៩៤៧ សង្គមខ្មែរយើង នៅតែជារបបសម្បូរណាញាសិទ្ធិដដែល ហើយប្រកបរបបអាណានិគមនិយមបារាំងសង្កត់ពីលើផង ។

ក្រោយសង្គ្រាមលោកលើកទីពីរ ១៩៤៥ លទ្ធិប្រជាធិបតេយ្យ បានរះហៀរហូរចូលមកប្រទេសខ្មែរយើង ក៏ដូចជា

បានជ្រាបចូលទៅប្រទេសចំណុះផ្សេង ៗ ទៀតដែរ ។ ប្រជាជាតិខ្មែរជាដាច់ខាត ត្រូវអនុវត្តទៅតាមរបបថ្មីនេះ ។ ប្រវត្តិសាស្ត្រប្រែប្រួលរបបគ្រប់គ្រងនេះ មានទៅក្នុងសុន្ទរកថាលោក អៀវ-កើស ប្រធានរដ្ឋសភានៅថ្ងៃ ២១ តុលា ១៩៤៦ ដូចតទៅនេះ :

«ថ្ងៃ ២១ តុលា គ.ស. ១៩៤៦ នេះ ជាវរតិថីជ័យមង្គលមួយ ក្នុងប្រវត្តិសាស្ត្ររបស់ជាតិខ្មែរយ៉ាងប្រពៃ ជាទីចងចាំក្នុងសន្តានចិត្តយើងទាំងឡាយ ទៅថ្ងៃក្រោយជាយូរអង្វែង ។

ការប្រែប្រួលរបបគ្រប់គ្រងទៅតាមកាលៈទេសៈ រមែងនាំវឌ្ឍនធម៌គឺសេចក្តីចំរើនមកឲ្យប្រជាជាតិដោយពិតប្រាកដ ។

ប៉ុន្តែក្នុងប្រទេសចំនួនច្រើន ទំរាំតែប្រែរបបគ្រប់គ្រងបាន ក៏តោងមានការបដិវត្តន៍ ដែលសម្រេចទៅបានដោយសន្តិវិធីជាការកម្រក្រៃលែង ការកែរបៀបគ្រប់គ្រងរមែងបានមកដោយប្រើកម្លាំង» ។

នៅថ្ងៃនោះព្រះករុណានរោត្តម-សីហនុ បាន ថ្លែងតបទៅលោកអៀវ-កើស វិញ នាំឲ្យយើងដឹងច្បាស់ នូវរបបសម្បូណ៌ាញាសិទ្ធិរាជ :

«តាំងពីច្រើនសតវត្សមកហើយ ច្បាប់សម្រាប់ប្រទេស ខ្មែរ គឺជាច្បាប់សម្បូណ៌ាញាសិទ្ធិរាជ ដែលព្រះរាជាទទួលអំ ណាចគ្រប់ចំពូកអំពីទេវស្ថាន ច្បាប់របៀបបូរាណនេះបណ្ដា ជនជាតិខ្មែរទទួលប្រតិបត្តិពីដើមរៀងមក ។

ប៉ុន្តែសង្គ្រាមក្នុងសាកលលោក ដែលផុតរលត់ទៅក្នុងឆ្នាំ ១៩៤៥ នេះ ដោយប្រជាធិបតេយ្យបានជ័យជំនះយ៉ាងមហិ បូណ៌ា នាំឲ្យមានកម្រើកគោលការណ៍ធំៗ ខ្លះ ដែលអស់ លោកជាមុខប្រធានរបស់ជាតិសហព័ន្ធ តាក់តែងឡើងក្នុងគ្រា ចលាចល ហើយដែលអស់លោកទាំងនេះ បានផ្សាយដល់ សាកលលោក ហើយបាចកប់ច្រើនលើកក្នុងចំណោមនានា ជាតិមកប្រជុំគ្នា ។

ប្រទេសកម្ពុជានឹងនៅក្រៅអំពីគំនិតថ្មីនេះមិនបាន ។

ហេតុដូច្នេះ គប្បីខ្ញុំជាម្ចាស់ផែនដី ឲ្យបណ្ដារាស្ត្រមានរដ្ឋធម្មនុញ្ញជាបឋម ដោយខ្លួនខ្ញុំតាមបែបផែនធូរទូលាយនឹងសេរីភាពដល់បណ្ដារាស្ត្រ ដើម្បីនឹងកែប្រែសម្បូរណាញាសិទ្ធិរាជ ដែលព្រះរាជាទទួលអំណាចពីទេវស្ថាន ទៅជារាជាធិបតេយ្យមានរដ្ឋធម្មនុញ្ញ ។ ក្នុងការគាត់តែងព្រះរាជក្រមធំសំខាន់យ៉ាងនេះ ខ្ញុំចង់ចិត្តថាគួរតែហៅបណ្ដារាស្ត្រអ្នកមានវិជ្ជាក្នុងព្រះនគរ តែងច្បាប់រដ្ឋធម្មនុញ្ញនេះ ហើយសួរយោបល់អ្នកដំណាងរាស្ត្រ មុននឹងសម្រេចសេចក្ដីជាដាច់ខាត ។។

តពីនោះមក ប្រជាជនខ្មែរ ក៏មានរដ្ឋធម្មនុញ្ញ ១៩៤៧ តែការអនុវត្តន៍តាមច្បាប់រដ្ឋធម្មនុញ្ញ ពុំដែលបានពេញលេញឡើយ ព្រោះពួកអាណានិគមបារាំង ដោយបានមុញ្ញពីចក្រពត្តិអាមេរិកាំង បានប្រើគ្រប់វិធីបង្កើតឧបសគ្គក្នុងប្រទេសយើង ហើយបំផ្លាញកុំឲ្យយើងទទួលផលជាក់ស្ដែងមានសិទ្ធិសេរីភាព ដែលបានចែងក្នុងរដ្ឋធម្មនុញ្ញនោះ ។

ការបែងចែកវណ្ណៈក្នុងសង្គមយើង បានផ្ដល់ឲ្យមានការបែកយោបល់ បែកពាក្យភាសា បញ្ជាក់យ៉ាងច្បាស់លាស់ក្នុងអក្សរសាស្ត្រខ្មែរយើង ។ យើងបានដឹងគ្រប់គ្នាថា មានពាក្យខ្មែរច្រើនបានន័យតែមួយ ព្រោះពាក្យទាំងនោះច្រើនប្រើសម្រាប់ក្រុមវណ្ណៈរបស់ខ្លួន ។

ឧទាហរណ៍.—

ស្ដេចយាង, លោកសង្ឃនិមន្ត, ពូដើរ, កូនដើរ, ឆាងដើរ ។

ស្ដេចផ្ទុំ, លោកសង្ឃសឹង, ពូសម្រាន្ត, កូនដេក, អាឆាងគេង ។

ស្ដេចសោយ, លោកសង្ឃឆាន់, ពូពិសា, កូនស៊ី, អាឆាងញ៉ាំ ។

យាង, សោយ, ផ្ទុំ,. ជាកិរិយាសព្ទ បានន័យថា ប្រើបានតែក្នុងឋានៈសម្រាប់ដំកើងកិត្តិយសក្សត្រ ។

និមន្ត, សឹង, ឆាន់: ជាពាក្យសង្ឃ ។ ការប្រើពាក្យនេះបានតែជាមួយសង្ឃ ។ យើងត្រូវយល់ទៀតថា ការទាក់ទងជាមួយព្រះសង្ឃនិងព្រះរាជា ប្រជាជនត្រូវបន្ទំប្រើអាកប្បកិរិយាលុតក្រាបដើរទាស្រដៀងគ្នា ។

ដើរ ពិសា សម្រាន្ត ស៊ី ផឹក... ជាពាក្យប្រជាជនពិតប្រាកដ ៗ ការនិយាយកាន់គ្នាមានសភាពស្មើគ្នា ៗ

គេង ញ៉ាំ ជាពាក្យក្រុមសម្រាប់និយាយទៅកាន់កូនក្មួយ ៗ ពាក្យនេះជាពាក្យថ្នម ៗ ពាក្យនេះបានផ្សាយជ្រាបទៅដល់ស្រែចំការខ្លះហើយ ៗ

ការបែងចែកពាក្យទៅតាមថ្នាក់តាមវណ្ណៈនេះ មានពិតប្រាកដគ្រប់សង្គមសក្តិភូមិក្នុងលោក ៗ ប្រវត្តិសាស្ត្របានបង្ហាញមកថា ក្រោយពេលដែលសង្គមណាមួយរលត់ ពាក្យសម្រាប់សង្គមនោះ អាកប្បកិរិយាសម្រាប់សង្គមនោះ ក៏រលត់ទៅជាមួយដែរ ៗ នៅស្រុកបារាំងក្រោយការបដិវត្តន៍១៧៨៩ សង្គមទុននិយម បានបំបាត់ពាក្យឋានន្តរសក្តិរបបសក្តិភូមិបោរាណ ហើយការទាក់ទងរវាងប្រជាជនទាហ៊ុនមកត្រឹមពាក្យហៅគ្នាទៅវិញទៅមកថា «លោក អ្នក» ៗ អាកប្បកិរិយាទំនៀមទម្លាប់លុតក្រាបក្នុងសក្តិភូមិ ក៏បានរលាយទៅជាមួយដែរ ៗ ប្រជាជនច្រើននិយាយទៅកាន់ប្រធានាធិបតីឬនាយក

វេជមន្ត្រី ឬ វេជ្ជមន្ត្រីនិយាយកាន់មកវិញតែត្រឹមពាក្យ «លោកនេះលោកនោះ» ៗ ក្នុងស្រុកសង្គមនិយម ដែលប្រជាជនមានវណ្ណៈកម្មករ កសិករ បានធ្វើជាម្ចាស់ ជាចៅហ្វាយនៃនយោបាយ, សេដ្ឋកិច្ច, វប្បធម៌, សង្គមកិច្ច បាននិយមពាក់ទងហៅគ្នាទៅវិញទៅមកថា: «សមមិត្ត» (មិត្តស្មើគ្នា) ហើយការលុតក្រាបខ្ពស់ទាបដើរពាក្យទេវមុន ក៏បានលោយលេត ៗ ប្រជាជនកម្មករស្តីទៅកាន់នាយកវេជមន្ត្រី, ទៅប្រធានាធិបតីហៅថា: «សមមិត្តនាយក» «សមមិត្តប្រធាន» «សមមិត្តស្តាលីន» «សមមិត្ត ម៉ៅ សេ ទុង» ។ល។

ការពិនិត្យមើលប្រវត្តិសង្គមខ្មែរយើង យ៉ាងស៊ើទូខេះអាចផ្តល់ឲ្យយើងចែកអក្សរសាស្ត្រខ្មែរដូចខាងក្រោមនេះ

១–អក្សរសាស្ត្រសម័យអង្គរ

២–អក្សរសាស្ត្រក្រោយសម័យអង្គរធ្លាក់តាមលង្វែកមកទុំនិង វេជ្ជកាលព្រះអង្គឌួង

៣–អក្សរសាស្ត្រនៅក្រោមនឹមដែកអាណានិគមនិយម

រ៍ ។

–អក្សរសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ មក

ដល់សព្វថ្ងៃ ។

–ꩻ○○–

# អក្សរសាស្ត្រខ្មែរសម័យអង្គរ

ចាប់តាំងពីមានប្រជាជាតិខ្មែរមកដល់សតវត្សទី ៧ (ព.ស) ខ្មែរយើងមានតែភាសានិយាយមិនទាន់មានអក្សរនៅឡើយ ។ ចាប់តាំងពីសតវត្សទី ៨(ព.ស) យើងមានអក្សរសរសេរខ្លះ តែមិនទាន់គ្រប់គ្រាន់ ។

អក្សរខ្មែរជំនាន់នោះ ច្រើនជាអក្សរសំស្ក្រឹតលាយចំរុះទំនងអក្សរខ្មែរបុរាណ ដែលមានកត់ក្នុងសិលាចារឹកទាំងនោះ (អក្សរចារនៅលើថ្ម) ។ លោកអៃម៉ូនញេ បានមើលអក្សរទាំងនោះរួចមុនគេ ។ ចំពោះអក្សរសិលាចារឹកទាំងនោះលោកស៊ីដេស .តាំងហ្វាំងសាលាបូព៌ាប្រទេសបារាំងបានឲ្យដឹងថា

«ភាសាសំស្ក្រឹតជាភាសាអ្នកប្រាជ្ញសម្រាប់ប្រើកត់ត្រា

ធ្វើបញ្ជីព្រះរាជវង្សានុវង្សប្រមហាក្សត្រ និងតែងសេចក្ដីសរសើរដល់ក្សត្រដែលទ្រង់សាងប្រាសាទ ។ អស់លោកដែលមានចិត្តសទ្ធាជ្រះថ្លាធ្វើអំណោយទាន ។ ភាសាមួយទៀតជាភាសាខ្មែរធម្មតា សម្រាប់កត់ត្រាពីរឿងការកសាងនិងសេចក្ដីរៀបរាប់ពួកមនុស្សបំរើនិងគ្រឿងប្រដាប់ប្រដាដែលវេរថ្វាយព្រះវិហារ ។

សេចក្ដីតែងជាភាសាសំស្ក្រឹត សុទ្ធតែរៀបរៀងជាពាក្យកាព្យសុទ្ធ គឺជាសេចក្ដីចងក្រងឲ្យមានចុងជួនដែលពួកអ្នកសិក្សា អក្សរសាស្ត្រឥណ្ឌៀហៅថា «កាវ្យៈ» ។

សិលាចារឹកទាំងនោះបានកត់ប្រវត្តិកសាងដុច្បាំងនៅជួកាលរបស់ស្ដេចណាមួយ ៗ ក្រៅពីនេះ សម័យអង្គរបានធ្វើឲ្យយើងស្គាល់ចម្លាក់គំនូរដោយចំណងជើងខ្លី ៗ នូវរឿងជាច្រើនដូចជារឿងព្រះរាម, ព្រះវិស្ណុ និងពុទ្ធប្រវត្តិជាដើម ។ ក្នុងចំណុចនេះទៀត លោកស៊ុដេស បានរកញែកប្រាប់យើងដូចតទៅនេះ :

...រូបចម្លាក់នឹងក្បាច់ចម្លាក់ស្អេកស្កះទុកគ ។ មកនោះនាំឲ្យយើងយល់ឃើញថា ក្នុងសម័យនោះមុខជាគេបានប្រែរៀងពីវប្បភណាអស់នោះ ចេញមកជាភាសាអ្នកស្រុកដែរ ។ មានសិលាចារឹកជាច្រើន និយាយទាក់ទងដោយប្រវត្តិរបស់ក្សត្រទាំងឡាយព្រមទាំងការត្រួតត្រាព្រះរាជអាណាចក្រខ្មែរសម័យនោះ មិនមែនជាមិនមានប្រើប្រាប់សម្រាប់ស្រុកទេ នឹងមានផលទៅសព្វសម្រាប់តុលាការដោយឡែកថែមទៀត ព្រមទាំងវិជ្ជាផ្សេងៗ ដោយមុខៗ របស់ខ្មែរមិនបាច់ពោលថាជាវិទ្យាសាស្ត្រដោយ ក៏គេបានចម្លងទុកជាក្បួនតូច ដូចយើងឃើញមាននៅរហូតមកដល់សព្វថ្ងៃ ។ នៅទីបំផុតពួកអមាត្យាធិបតេយ្យ ដែលធ្វើអង្គរុងរឿងយ៉ាងពន្លឹកដូច្នោះ មិនមែនគ្មានវប្បធម៌ទេ ឯវប្បធម៌នោះសោតទៀត ក៏ប្រហែលជាមិនឆ្ងាយចេញតែដោយភាសាសំស្ក្រឹតដែរ ។ អក្សរសាស្ត្រអស់នេះ មានកើតឡើងជាពិតប្រាកដ ប៉ុន្តែមិនមានសេសសល់ដល់មុខយើងបានសោះឡើយ ដោយហេតុ

សម័យនោះគេប្រើសរសេរតម្រាផ្សេង ៗ ដោយដីសពងលើស្បែកសត្វ ដែលធ្វើឱ្យមានពណ៌ខ្មៅ ម៉្លោះហើយតម្រាអស់នោះក៏រលប់បាត់អស់ឥតសល់ គឺអន្តរាយដោយសំណាចសត្វល្អិតៗនិងធាតុអាកាស មានតែជាតិថ្មទើបទប់ទល់គង់នៅបាន ។

យើងបានសង្កេតឃើញតាំងពីសម័យនោះមក អក្សរខ្មែរយើងបានប្រែមានវឌ្ឍនធម៌ចំរើនជាច្រើន ៗ លោកសឺដេស បានឲ្យដឹងថែមទៀតថា:

...វត្ថុដែលគង់វង្សនៅជាបែបការ្យធម៌សម័យមុខណាខាងសាសនាព្រាហ្មណ៍គឺ:

ក– រឿងរាមកេរ្តិ៍ ដែលជាសេចក្តីប្រែចេញអំពីរឿងរាមាយណៈ ថែមតាំងប្រែមិនបានចប់សព្វគ្រប់ផង ហើយថែមតាំងបំប្រួញជារឿងខ្លី ១ ដែលគេតែងនិយាយលេងជាញឹកញយ ៗ

ខ– គឺគម្ពីរត្រៃភេទត្រៃភូមិដែលមានដោយរដាច់រដោច ៗ

ដើម្បីនឹងរៀនឲ្យស្គាល់អក្សរសាស្ត្រខ្មែរទៅសម័យអង្គរ ឲ្យបានជ្រៅជ្រះ ត្រូវតែយើងរៀនឲ្យស្គាល់ ឬ យល់អក្សរចារឹកថ្មទាំងប៉ុន្មានៗ ថ្មួយដុំៗ នៅអង្គរមានពាក្យនិយាយប្រាប់យើងច្រើនណាស់ ខាងរបៀបគិតនិកខាងរបៀបសិល្បៈ ខាងអក្សរសាស្ត្រទាំងបានបញ្ចាញឲ្យយើងឃើញថា „វ៉ន” ដែលជាដីដូនជីតាយើង ខំតស៊ូស្វិតស្វាញយ៉ាងអស្ចារ្យៗ ត្រូវតែយើងទាំងអស់គ្នាយកគម្រាប់ស្វិតស្វាញ ខំពុះពារឧបសគ្គដែលចក្រពត្រអាមេរិកាំងបង្កើតឡើងទាំងប៉ុន្មាន ៗ យើងត្រូវបេជ្ញាការពារសន្តិភាពឯករាជ្យប្រជាធិបតេយ្យ ដើម្បីយើងលំអការរស់នៅរបស់យើងឲ្យមានសិល្បៈ អក្សរសាស្ត្រយុត្តិធម៌ពិតប្រាកដ ៗ

# អក្សរសាស្ត្រខ្មែរ ក្រោយសម័យអង្គរឆ្លង តាមលង្វែកមកឧដុង្គរជ្ជកាលព្រះអង្គឌួង

ក្រោយពីសម័យអង្គររុងរឿង ខាងសិល្បៈល្បីល្បាញ ក្នុងសាកលលោក ប្រទេសខ្មែរយើងបានជួបប្រទះនឹង សង្គ្រាមជាញឹកញាប់ ណាច្បាំងទល់នឹងប្រទេសជិតខាង ណាច្បាំងដណ្តើមបល្ល័ង្កគ្នាក្នុងស្រុក ។ នៅក្នុងរយៈសង្គ្រាម ដូច្នេះប្រជាជនត្រូវគេបកៀសសឹកឬត្រូវកេណ្ឌធ្វើទាហាន ។ ប្រជាជនគ្មានសេរីសិទ្ធិ ។ វណ្ណៈខ្ញុំគេ អ្នកងារមាននៅក្នុង សង្គមខ្មែរយើង ។

ខាងសិល្បៈ ក៏មិនឃើញមានធ្វើអ្វីឲ្យធំដុំឡើយ ។ ឬកណាតែធំៗ នៅសម័យអង្គរបានរលាយទៅវិញ បានគប់

ក្លួចពោលក្នុងព្រៃជាចំណីក្ដួជាតិ ៗ ខាងសាសនាប្រជាជននៅកាន់ពុទ្ធសាសនា ៗ

ឯចំណែកអក្សរសាស្ត្រវិញ ក្រៅពីមានរឿងស្រង់ពីគម្ពីរពុទ្ធសាសនា យើងអាចឃើញមានស្ត្រាល្បែងច្បាប់ក្រម ក្តីកាល ដែលក្រងចងជាស្ត្រាស្លឹករឹត និងរឿងព្រេងនិយាយត ៗ គ្នា ៗ រឿងទាំងអស់នោះមិនដែលដាក់ឈ្មោះអ្នកនិពន្ធ ហើយមិនដឹងជាសរសេររៀបរៀងនៅក្នុងពេលណាផង ៗ

មុននឹងពិនិត្យមើលអក្សរសាស្ត្រខ្មែរយើង សម័យនោះមានអត្ថរសដូចម្ដេច ចងជាប៉ុន្មានចង្កោម យើងសូមពិនិត្យមើលការសិក្សានៅសម័យសក្ដិភូមិនោះបន្តិច ៗ ការសិក្សាសម័យនោះ បានមានសល់ស្លាកស្នាមនៅក្នុងសង្គមយើងសព្វថ្ងៃនេះ ដូចយើងអធិប្បាយខាងក្រោមនេះ ៗ

ក) របៀបសិក្សា — នៅសម័យនោះរបៀបសិក្សាធ្វើទៅតាមរបបសក្ដិភូមិៗ កូនខ្មែរភេទប្រុសអាយុ៩ ឬ ១០ឆ្នាំ

បានចូលទៅនៅវត្ត ។ ក៏ទៅនៅបំរើលោកគ្រូ ដាំទឹក ដងទឹក ពុសខុសតាមលោកទៅសូត្រមន្ត ទៅឆាន់ទៅទេសនា ។ល។

ការរៀនសូត្រគ្មានពេលម៉ោងហ្មត់ចត់ទេ ។ ក្មេងនៅជាមួយលោកគ្រូណាយកចិត្តទុកដាក់ក៏បានចេះមើលសរសេរខ្លះទៅ ។ ធម្មតាគេសង្កេតឃើញក្មេងចេះរៀនចាំមាត់ហួរ តែមើលអក្សរឬសរសេរផងមិនកើត ។

អាយុ១៥ឬ១៦ឆ្នាំ ក្មេងនោះក៏បានប្រែភេទចូលទៅបួសជាសាមណេរ បាន៥-៦ឆ្នាំក៏បានបំពេញជាភិក្ខុភាពឬ ឬក៏សឹករៀបចំផ្ទះសម្បែងប្រពន្ធកូនវិញ ។

«បណ្ឌិត» ទាំងនោះមានខ្លះមកប្រកបរកការធ្វើស្រែ ខ្លះទៀតក៏បានទៅផ្គាប់បុណ្យបានធ្វើស្មៀនមន្ត្រី ។ល។ វិសេសគ្នាតរៀនក៏បានចេះជ្រៅជ្រះដែរ ដោយខ្លះបាន ទៅនៅប្រទេសសៀម ។

គ្រូអាចារ្យ សម័យនោះវត្តលោកសង្ឃជាសាល [illegible]លោកសង្ឃជាគ្រូបង្រៀន ។ លោកសង្ឃជាអ្នក

ជឿនលឿនជាងគេក្នុងដំបូន្មានស្រែចំការ ។ លោកច្រើនផ្សាយធម៌ព្រះពុទ្ធឲ្យជឿឋានសួគ៌ និព្វាន «ឲ្យស៊ុខចិត្តទទួលអត់ទ្រាំវេទនា ដោយជឿលើកម្មពីបុព្វេ អន្ទោលតាមប្រាណមកគ្រប់ជាតិ» ។ ក្រៅពីនោះ លោកបានផ្សាយបង្រៀនជាដំបូងច្បាប់ក្រម កេរ្តិ៍កាល ពាក្យចាស់ ស្ត្រាល្បែងជិនវង្ស លក្ខណវង្ស ។ល។ អាកប្បកិរិយារៀនសូត្រគឺច្រើនចូលចិត្តបង្ហាត់សិស្សឲ្យចេះ «ប្រើទនលំពោន កុំបីមានផ្គងប្រាជ្ញបុណ្យផង កើតដោយប្រណិប័តន៍» ពោលគឺត្រូវរៀនឲ្យចេះលុតក្រាបដើរចាលួនប្រណម្យ លុតជង្គង់នៅចំពោះមុខលោកធំ ។

ក) កម្មវិធី–ក្នុងវេរសម័យនោះច្រើនជួបប្រទះស៊ើរគ្រប់គ្នា នូវការរៀនសូត្រផ្សេង ៗ ដូចតទៅនេះ :

១- រៀនមន្តអាគមអូមការមស្នេហ៍ រៀនផ្សេង ៗ ដែលជាការគ្មានសមហេតុសមផលចំពោះសម័យយើងសព្វថ្ងៃ រៀនធ្វើគ្រឿងហ្វូមពិសពួយ ត្រីអណ្តាត ។ល។

២-រៀនធ្វើគ្រួចាយកាត់យល់សប្តិ ។ តែក្បួនហោរនេះមិនបានគុតឆាប់ទេ ជាហេតុឲ្យមានពាក្យខ្មែរយើងចុកណាធ្វើយប្រាប់ថា «គូតនៅហោរ ចោរនៅផាន» ។

៣-រៀនទព្វសូចស៊ើងណាស់ ។ ចំនួនតិចណាស់ដែលបានរៀនក្បាច់ចិន ហើយច្រើនទន្ទេញមេលេខជាភាសាចិន ។ គេរៀនតែលេខបូកគុណ សងខែតព្រួល ។ ជាការចប់ ។ ចំណោទមិនសូវរៀនទេ ។

៤-ខាងអក្សរសាស្ត្រវិញគេរៀនច្បាប់គ្រម កេរ្តិ៍កាលកូនចៅ ស្រ្តីល្បែង ស័ន្ធស័ល្បជ័យ ជិនវង្ស ស្រ្តីដុច គម្ពីរទេសនា មហោសថ សព្វសិទ្ធជាដើម; ។ គេរៀនឲ្យមើលដាច់ដើរនិយាយប្រាប់គ្នាជាការចប់ ។ តិចណាស់គេរៀនពិចារណាលើច្បាប់ទាំងនោះឲ្យយល់ ឃើញច្បាស់លាស់នូវហេតុនឹងផល ។

វិធីរៀនដែលផ្អែកទៅលើការទន្ទេញឡូ ។ មិនសូវមាន

ការពិចារណាបានជម្រុញប្រជាជនយើងឲ្យជឿថា រឿងស្រាល្បែងជាការពិត ឲ្យជឿថាអ្នកកាន់អំណាចជាពោធិសត្វ ជាដំណាងព្រះពុទ្ធ ។

ការសិក្សាដែលជាអង្គការសក្តិភូមិនេះ បានរាំងរាប្រជាជនយើងឲ្យនៅអណ្តែតអណ្តូង ជឿនូវការមិនសមហេតុសមផល ។ ការសិក្សាផ្អែកទៅលើជំនឿមិនមែនកើតមាននៅក្នុងសង្គមសក្តិភូមិខ្មែរម្នាក់ឯងឡើយ ។ ក៏បានកើតស្រដៀងគ្នានៅក្នុងសង្គមសក្តិភូមិក្នុងលោក ។ នៅក្នុងសង្គមសក្តិភូមិអឺរ៉ុប អ្នកកាន់អំណាចបានបង្ហិលប្រជាជនឲ្យជឿថា រាជាជាដំ-ណាងព្រះម្ចាស់សួគ៌ ។ នៅសង្គមសក្តិភូមិអេហ្ស៊ីប គេបានធ្វើឲ្យប្រជាជនយល់ថា «ហ្វារ៉ាអុង» (ស្តេច) ជាដំណាងទេវតាមហាម៉ាត់ ។ សង្គមសក្តិភូមិជប៉ុន គេបានបោកបញ្ឆោតប្រជាជនថា «មីកាដូ» ជាដំណាងព្រះអាទិត្យ ។

តែប្រវត្តិសាស្ត្របានធ្វើឲ្យយើងឃើញជាក់ស្តែងថា វិធីបង្រៀនរបៀបសក្តិភូមិនេះ មិនបានទប់ទល់ប្រជាជនឲ្យនៅ

អណ្ដែតអណ្ដូងហើយទេ ។ ការចំរើនលូតលាស់នៃអក្សរសាស្ត្រ បានបណ្ដុះផ្ទះប្រជាជនឲ្យមានគំនិតប្រាជ្ញថ្មី ហើយឲ្យទំនើបជាងពីដើមមក ។

## អក្សរសាស្ត្របែកជាបង្គោលធំពីរ

តាមការពិនិត្យសង្គមខ្មែរយើង និងការសិក្សាព្រមទាំងការស្រាវជ្រាវផ្សេង ៗ នូវទំនៀមទម្លាប់ដែលនៅសល់ពីមុនបានធ្វើជាស្ពានប្រវត្តិយាយគ ។ ក្នុងពេលនោះ យើងអាចចែកអក្សរសាស្ត្រខ្មែរយើងសម័យនោះ ជាពីរបង្គោលធំ ១ ផ្ទុយប្រឆាំងគ្នានឹងការពារបំរើវណ្ណៈរៀងខ្លួន :

១)– អក្សរសាស្ត្រផ្សាយពីក្រវ៉ាំងណា ១ ដែលច្រើនទទួលការឧបត្ថម្ភពីក្រុមលទ្ធិកនិងទុង្គ ។ អក្សរសាស្ត្រដែលនេះបំរើវណ្ណៈខ្លាំងពូកែនៃការពារវណ្ណៈនោះ ។

២)– អក្សរសាស្ត្រប្រជាជន ជាអក្សរសាស្ត្របដិវត្តន៍

ផ្ទុយនឹងអក្សរសាស្ត្រផ្នែកទីមួយ ។ អក្សរសាស្ត្រនេះ មិនបានចងក្រងជាស្ត្រាជាក់លាក់ទេ ហើយយើងច្រើនឲ្យឈ្មោះថារឿងព្រេង ។

x

x x

## ១- អក្សរសាស្ត្របដិកិរិយា

-អក្សរសាស្ត្របដិកិរិយា ផ្សាយចេញពីលំផ្ទែកនឹងទុដ្ឋគ ជាអក្សរសាស្ត្រកើតឡើងពីវណ្ណៈ ខ្ញាំងភ្ញើករៀបរៀង ហើយមានគោលបំណងធំការពារប្រយោជន៍វណ្ណៈខ្លួននោះឯង ។ គេយកចិត្តទុកដាក់បង្ហាត់បង្រៀនប្រជាជនឲ្យចេះក្បួនច្បាប់ទាំងនោះណាស់ ។ គេមានឲ្យបានចងក្រងជាស្ត្រាស៊ឹកកែតដាក់នៅគ្រប់វត្ត ហើយគេបង្រៀនឲ្យចេះដឹងជឿតាមក្បួននោះតៗគ្នាមក ។ ក្នុងពពួកអក្សរសាស្ត្រផ្នែកនេះយើងអាចរាប់រឿងសាសនា ច្បាប់ក្រមប្រុស, ស្រី, ត្រីនេត្រ ច្បាប់កិនកេរ្តិ៍ ស្ដាល្បែង, រឿងទាវ-ឯក ។ល។

ក) រឿងសាសនា– រឿងនេះច្រើនជារឿងដកស្រង់ពីគម្ពីរជាតក ដែលច្រើននិទានពីកំណើតព្រះពុទ្ធ កាលនៅជាពោធិសត្វនៅគ្រប់ជាតិ រឿងដែលព្រះសង្ឃយកទៅផ្សាយទេសនាឲ្យប្រជាជនជឿ មានរឿងសព្វសិទ្ធិ រឿងមហាសថ រឿងព្រះវេស្សន្តរ មេទ្រីបា ក្រិស្នាបាជាលី រឿងកាកី រឿងពិម្ពា ពុទ្ធប្រវត្តិ ។ល។

ដើម្បីពន្យល់ប្រជាជនឲ្យជឿកំណើតនៃទុក្ខវេទនា ព្រះសង្ឃច្រើនទេសនាផ្អែកទៅលើ កម្មពីអតីតអន្ទោលតាមប្រាណ ហើយច្រើនយករឿងជាតកទាំងនោះជាឧទាហរណ៍ ។ ឯយើងសព្វថ្ងៃឃើញទុក្ខវេទនាប្រជាជនគឺកើតមកពីការជិះជាន់របស់ចក្រពត្រ ពីការបោកបញ្ឆោតរបស់នាយទុនទៅវិញ ។

ខ) ច្បាប់ក្រមប្រុសស្រី– ច្បាប់នេះកូនខ្មែរដែលបានទៅរៀននៅវត្តត្រូវតែបានរៀនសូត្រគ្រប់គ្នា មានខ្លះចាំសូត្រ

បានមិនបាច់មើលស្ត្រាផង ។ ច្បាប់នេះជាក្បួនមួយ បំពាក់កិរិយាកូនខ្មែរតាំងពីកុមារទៅ ឲ្យចេះដាក់ឫកពាទន់ភ្លន់ដើរពា ស្របទៅតាមច្បាប់នៃវណ្ណៈខ្លាំងពូកែក្នុងពេលនោះ ។

នៅក្នុងច្បាប់ក្រម គេបង្រៀនកូនខ្មែរឲ្យចេះលុតក្រាប «ប្រើទុនលំទោន កុំបីមានគ្នង ប្រាជ្ញាបុណ្យផង កើតដោយប្រណិប័តន៍» ច្បាប់ប្រុសបានប្រដៅកូនប្រុសឲ្យចេះផ្គាប់ផ្គុន នឹងឲ្យប្ដូរជីវិតបំរើវណ្ណៈខ្លាំងពូកែលុះអស់ជីវិត ។

ច្បាប់ស្រីបានតម្កើងប្រុស ហើយបង្គាប់ទៅស្រីឲ្យនៅគ្រប់លក្ខណ៍ជាទាសី ដោយកុំឲ្យហ៊ានឆ្លើយតបទៅនឹងប្ដី គង់តែប្ដីធ្វើខុសឆ្គងលើដូចម្ដេចក៏ដោយ ។ ច្បាប់ស្រីដែលជាស្នាដៃបុរសកវី បានដាក់ស្រីឲ្យចុះញ៉មនឹងប្រុសយ៉ាងអស់ខ្នាត ។ នៅក្នុងសង្គមនេះ គេច្រើនមាក់ងាយស្រី ហើយគេច្រើនទុក «ស្រីដូចស្ពាន់ ប្រុសដូចពេជ្រ»

ច្បាប់ដំពូកនេះមានច្រើនណាស់ យើងមិនបាច់យកមករៀបរាប់ទាំងអស់ទេ ។ យើងគ្រាន់តែឲ្យដឹងថា ច្បាប់ទាំង

នោះគ្មានវិមសាអ្វីក្រៅពីប្រដៅប្រជាជនឲ្យចេះលុតក្រាបនៅចំពោះមុខវណ្ណៈខ្ពង់ខ្ពស់តែនោះតែប៉ុណ្ណោះ ។

ក) ច្បាប់កឹងកង្រ្កែ— ដែលហៅថាច្បាប់កឹងកង្រ្កែ គឺរឿងមេបៀកាត់ក្តី ។ រឿងទាំងនេះច្រើនជាគំរូសម្រាប់តុលាការ ។ តាមសន្និដ្ឋានមើលទៅប្រហែលជានៅសម័យនោះខ្មែរយើងមិនទាន់មានបទច្បាប់ព្រហ្មទណ្ឌ; ច្បាប់រដ្ឋប្បវេណីនៅឡើយ ព្រមទាំងមិនទាន់មានសាលាតុលាការជំនុំជំរះដូចយើងសព្វថ្ងៃនេះផង ។ ក្នុងរឿងកឹងកង្រ្កែគេច្រើននិទានពីគូក្តីទាស់គ្នា ប្តឹងទៅក្រមយោមរាជឲ្យកាត់ ។ មិនដាច់កាត់មិនរួច ក៏តាំងនាំរឿងនេះប្តឹងដល់ព្រះរាជា ។ ព្រះរាជាក៏កាត់សេចក្តីចុងបំផុត ។ ជាធម្មតាគេច្រើនលើកបង្ហាញថាការវិនិច្ឆ័យរបស់ព្រះរាជាទាំងប៉ុន្មានយុត្តិធម៌ទាំងអស់ ។ រឿងនេះមានគោលធំក្តាប់ប្រជាជនឲ្យយល់ឃើញថា ព្រះរាជាជាអ្នកទសពិធរាជធម៌ កាត់សេចក្តីត្រឹមត្រូវយុត្តិធម៌រឿងស្មុគ្រស្មាញទាំងប៉ុន្មាន

រឿងកឹងកន្ត្រៃមានច្រើនដូចជារឿងបុរសបាញ់ខ្ទង់ រឿងអាមាត្យរក្សាញ៉ព្រះរាជទ្រព្យ, រឿងចៅម្ចាស់ផ្ទះនឹងរឿងចៅសំបត ។ល។

ឃ) ស្ត្រាល្បែង — ដែលហៅថាស្ត្រាល្បែង គឺរឿងដែលច្រើនសរសេរជាពាក្យកាព្យ ហើយមានរឿងខ្លះដែលចងជាច្រើនខ្សែ ។ រឿងទាំងនោះ ច្រើនយកទៅបង្ហាត់បង្រៀនកូនខ្មែរនៅវត្ត ។ ល្ខោនបាសាក់, យីកេ, ល្ខោនហ្មង ក៏ច្រើនយករឿងអស់នោះមកលេងដែរ ។ ដូច្នេះ រឿងស្ត្រាល្បែង បានជ្រាបចូលទៅក្នុងប្រជាជនទាំងស្រីទាំងប្រុស ។ រឿងស្ត្រាល្បែងមានជិនវង្ស, រត-នាវង្ស, ចិត្រសង្ហា, ហង្សយន្ត សង្ខសិល្បជ័យ ។ល។ ស្ត្រាល្បែងច្រើនជារឿងដែលគេលើកស្រវៀងគ្នា ដូចតទៅនេះ ៖ «មានកូនស្តេចមួយកើតមក កាលនោះកុមារត្រូវម្តាយចុង ឬ មាបណ្តេញចេញ ឬ យកទៅសម្លាប់ចោល ។ តែធម្មតាមានទេវតា ក្នុងខ្លួនមកជួយនាំកុមារនោះទៅកន្លែងព្រៃ

ជួបការស្រមៃតាមឥសី ឬ អ្នកចិត្តសប្បុរសផ្សេងទៀត យកទៅបង្រៀនមន្តអាគម «បេះដប់, ប្រក់ពល, ហោះខ្លាំងពូ-កែ» ។ ដល់កម្លោះទៅជួបនឹងកូនស្រីយក្ស ឬ កូនស្រីស្ដេចដូចគ្នា ក៏ចាប់ចិត្តស្រឡាញ់ ។ ចាប់ពីពេលនោះក៏ដើរទៅជាមួយស្រីមានព្រាត់ប្រាស់គ្នា ដោយយក្សពុកកូនស្រីពង្រាត់ ឬមួយទៀតដោយយក្ខិនីណាមួយមកលួងលោមឬក៏ស្រឡាញ់កូនស្រីគេក្រោយទៀត ។ ការព្រាត់ប្រាស់នេះច្រើនបណ្ដាលឲ្យស្ដេចដើរតាមឬដោះខ្លួន ក៏ត្រូវកើតមានសង្គ្រាមច្បាំងគ្នា ។ គេកេណ្ឌទ័ពមនុស្ស ទ័ពស្វា ឲ្យវាយនឹងទ័ពយក្ស ដើម្បីដណ្ដើមស្រីឬការពារស្ដេចនោះ ។ ហើយធម្មតា កូនស្ដេចដែលរៀនពីឥសីច្រើនឈ្នះជាដរាប ។ ដល់ចប់រឿង គេច្រើនប្រៀបប្រដូចថាស្ដេចនោះជាពោធិសត្វ ហើយអគ្គមហេសីជានាងពិម្ពាដូចក្នុងរឿងជិនវង្ស គេប្រដូចថា ជិនវង្សយោនយកកំណើតជាព្រះពុទ្ធ ហើយនាងចន្ទសុរិយាជាតិក្រោយមកកើតជានាងពិម្ពា» ។

រឿងប្រៀបប្រដូចនេះបានបំពេប្រជាជន ដែលខ្វះក្តីពិចារណាឲ្យជឿថា ព្រះរាជាជាតំណាងព្រះពុទ្ធឬទេពលអំណាចពីទេវស្ថានមក ហើយឲ្យប្រជាជនសុខចិត្តទទួលរស់នៅកោតក្រែងអំណាចសម្បូណ៌ញាសិទ្ធិរាជ ។

ម្យ៉ាងទៀតក្នុងរឿងស្រ្តាល្បែងអ្នកកវីច្រើនផ្ទុកទៅលើយល់សុបិ លើអំណាចឫទ្ធិនៃមន្តអាគមប្រកំពល, ហេះហោះ ជ្រែកដី ដែលជារឿងកើតឡើងគ្មានសមហេតុសមផល ។

តែក្នុងពួកស្រ្តាល្បែងទាំងនោះ យើងឃើញមានរឿងខ្លះ មានការបំភ្លែកឃ្លាតបន្តិចពីអាគមមន្ត ហើយផ្ទុកមកលើស្នាដៃនៃវិទ្យាសាស្រ្តទៅវិញ ។

នៅក្នុងស្រ្តាជិនវង្សមានរឿងថា ..ជិនវង្សនិងបុមសុរិយា បាននាំគ្នាជិះហង្សយន្តហោះ ដល់កណ្តាលសមុទ្រហង្សយន្តជាប់ខ្សែ អ្នកជិះទាំងពីររូបក៏បានធ្លាក់ចុះទៅក្នុងសមុទ្រព្រាត់ប្រាសគ្នា ។ នៅក្នុង ..ស្រ្តាហង្សយន្ត.. ក៏

មានរឿងមួយកវីខ្លួននិយាយពីជិះហង្សយន្តដូច្នេះដែរ ។

នៅក្នុងរឿង «នាងពីរដណ្តប់នាគ» យើងក៏បានឃើញរឿងនាងគង្គរី នាំខ្ទើសេនចូលក្នុងរាជវាំង ហើយពន្យល់ខ្ទើសេនអំពីភ្នែកដែលគេខ្វេះយកមកទុក ហើយទឹកថ្នាំដែលគេអាចយកទៅដាក់មើលភ្នែកនោះ ប្រើការបានដូចមុនវិញ ។

ក្នុងរឿងខាងលើនេះយើងអាចសន្មតបានថា អ្នកកវីខ្មែរចំរើនខ្លះជំនាន់នោះ បានយល់ស្មានមកលើវិទ្យាសាស្ត្រទៅអនាគត ហើយជឿមន្តអាគមដែលគ្មានសមហេតុសមផល ។ ចំពោះការស្មានដាក់ទៅលើវិទ្យាសាស្ត្រនេះ យើងអាចប្រៀបអ្នកកវីខ្មែរខ្លះជំនាន់នោះ ទៅនឹងអ្នកនិពន្ធបារាំងម្នាក់ឈ្មោះ ស៊ូល-វើន ដែលបានសរសេរសៀវភៅនៅសតវត្សទី ១៩ ស្មានជឿទៅខាងវិទ្យាសាស្ត្រ ។ ការស្មានរបស់អ្នកកវីជំនាន់នោះ ឥឡូវបានជួបនឹងការដាក់ស្តែងពិត

ប្រាកដ ដូចជាយើងមានយន្តហោះ និងថ្នាំសម្រាប់បន្តក់ភ្នែកខ្វះទៅហើយ ក្នុងសម័យយើងឥឡូវនេះ ។

ង) រឿងទុំទាវ ឯក— រឿងនេះជារឿងពិតជាក់ស្តែងមានក្នុងប្រទេសខ្មែរយើង នៅជំនាន់ប្រហែលសតវត្សទី១៥ ។ រឿងនេះបញ្ជាក់ឲ្យយើងឃើញរបបសក្តិភូមិ នៅប្រទេសយើងក្នុងពេលនោះ ។ យើងសូមសរុបរឿងនេះសិន ។ យើងសូមបញ្ជាក់ថា យើងសរុបតាមសាស្ត្រាស្លឹករឹតបុរាណ ។ នាយទុំកើតនៅបាភ្នំ ។ ដល់អាយុគ្រប់រៀន ម្តាយយកទៅឲ្យនៅវត្តព្រះវិហារធំ ។ ទុំវៃឆ្លាតរៀនអាគមពូកែ ស្មូត្រ ទេសនាសំឡេងបាន ។ បួសជាសាមណេរ នេនទុំនឹងនេនពេជនៅវត្តជាមួយគ្នា ។ ពេលមួយក៏នាំគ្នាលាលោកគ្រូបររទេះទៅលក់គោកទៅស្រុកត្បូងឃ្មុំ ។ នៅដល់ភូមិដើមវាល (ស្ទឹងសព្វថ្ងៃ) នេនទុំនឹងនេនពេជ ឈប់... ក់នៅ ហើយនេនទុំដែលមានរូបសម្បត្តិ បានស្មូត្រទេសនាពិរោះល្បីល្បាញ បានក្តីរាប់អានពីអ្នកស្រុកទាំងស្រី ទាំងប្រុស ទាំ

ចាស់ទាំងក្មេង ។ នៅពេលនោះនាងពាវដែលជានារីល្បី ល្អក្រញាងរូបសម្បត្តិដែរ ក៏បានដំណឹងពីនាងនោជាកិលៀង ថាមាននេនពូកែស្វូត នាងក៏ទៅស្តាប់ធម៌ទេសនា ស្វូតដែរៗ នាងពាវចាប់ចិត្តស្រឡាញ់នេនខុម បានបូជាផាហុំត្រឡាប់ ប្រេងទឹកអប់ខ្លឹមចន្ទន៍ឈ្ងុយរំភើប ធ្វើឲ្យនេនខុមនៅជាសង្ស័យ រកឋានសួគ៌និព្វានផងលែងឃើញ ម្ល៉ោះហើយ នេនខុមតែង តែមានការនឹកទៅនាងពាវជានិច្ច ៗ នាំនេនពេជត្រឡប់ទៅ វត្តវិញ ខុមបានបបួលគ្នាលាលោកគ្រូសឹកៗ លោកគ្រូបើកឲ្យ នេនពេជសឹកៗ ឯចំណែកនេនខុមមិនព្រមឲ្យសឹកទេ ព្រោះ ទាយៈទោះឃើញថាសឹកទៅមានអន្តរាយ ៗ ខុមមានះទៅ ពឹងញោមស្រីឲ្យមកជួយអង្វរលោកគ្រូ ៗ នៅតែឃាត់ ៗ តែ ខុមមិនយល់ព្រមផង ក៏បានទៅដោះស្បង់ចីពរនៅក្រោម ដើមឈើពាល់តែបាន ៗ

ក្រោយដែលនេនខុមត្រឡប់ទៅវត្តវិញ នាងពាវ ខ្សឹបហ៍រំពឹងសេចក្តីស្នេហារបស់នាងប្រាប់ទៅនោ ៗ ពាវ

ព្រួយចិត្តដោយម្ដាយនាងឈ្មោះដួងជាន់ បានលើកនាងទៅឲ្យម៉ឺនង៉ួនកូនអរដូនចៅហ្វាយស្រុកត្បូងឃ្មុំ ។

ទុំសឹករួចកាលណា សូមស្មាលាទោសលោកគ្រូ សូមលាម្ដាយទៅត្បូងឃ្មុំជាមួយពេជ ។ ទុំបានរកឱកាសទៅជួបទាវហើយបានរួមកក់គ្នា ប្ដេជ្ញាស្លាប់រស់ជាមួយគ្នាលុះអស់មួយជីវិត ទាវមិនព្រមលុះតាមម្ដាយឲ្យខ្លួនទៅម៉ឺនង៉ួនទេ ។

នៅសម័យនោះ ព្រះចៅខ្មែរព្រះនាមព្រះរាមា បានឮល្បីទុំពូកែច្រៀងហើយពេជពូកែខ្លុយ ក៏បានចាត់អាមាត្យឲ្យទៅកេណ្ឌយកមកលង្វែក ។ ទុំបានលានាងទាវហើយជាមួយពេជទៅបង្គំលាម្ដាយ រួចក៏ចុះទូកចូលគាល់ស្ដេចក្រុងលង្វែក ។

ខ្លុយពេជនិងចម្រៀងទុំ បានធ្វើឲ្យព្រះរាមាពេញចិត្តជាខ្លាំង ក៏បានលើកទុំជាម៉ឺនឯក ។ ក្រោយមកទៀត ព្រះរាមាបានចាត់នាម៉ឺនមន្ត្រី ឲ្យដើរមើលស្រីណាល្អ ដើម្បីយកមកធ្វើស្នំមហេសី ។ នាងទាវដែលមានរូប

សម្បត្តិក៏ត្រូវអាមាត្យចាប់យកមកលង្វែក ឯម៉ឺនង៉ួននឹងអជួន មិនហ៊ានទទឹងព្រះរាជបញ្ជា ពិតមែនតែបានលើកស្វារួច ហើយ ។

យាយផាន់នាំនាងទាវមកលង្វែក ។ នាងទាវមិនបានត្រេកអរនឹងមកធ្វើស្នំមហេសីទេ នាងនឹកទៅគូកំសត់ ទុំជានិច្ច ឯចំណែកយាយផាន់ក៏ខិបខុបត្រេកអរខឹង លង្វែក ដែលគាប់ប្រសើរនឹងនាងទាវ ។ ទៅដល់វាំងក៏ចូល គាល់ព្រះរាមា ។ ទុំឃើញនាងទាវដោយក្តីស្នេហាគូកំសត់ ភ្លេចអំណាចព្រះរាមា ហើយក៏ប្រៀងទូលស្តេចថា ទាវជាគូ សង្សារខ្ញុំ ។ ព្រះរាជាឮដូច្នោះ ខឹងនឹងទាវដោយហ៊ានស្រ-ឡាញ់ប្រុសចិត្តឯង តែមិនបានយកទោសផងទេ បែរជាសួរ ដណ្តឹងទៅទាវនឹងទុំឲ្យនិយាយប្រាប់ទៅវិញ ។ ទុំនឹង ទាវឆ្លងស្របមូលមាត់គ្នាថាស្រឡាញ់គ្នាពិត ព្រះរាមាក៏បាន រៀបការឲ្យជាប្តីប្រពន្ធហើយឲ្យទុំជាម៉ឺនឯក នៅគាល់ជា ពជបំរើ ។

យាយផាន់ដែលជាចាស់ជរាបានបុណ្យសក្តិ ឃើញចៅបាន់មកខ្ញុំ កើតក្តៅក្រហាយ ក៏លាត្រឡប់មកភូមិដើមខាលវិញ ៗ មកដល់ផ្ទះគាត់និយាយជាមួយអាជួន ឲ្យដណ្តឹងចៅទៀត ហើយរកឧបាយកលពង្រាត់ចោរពីឯណេះ ប្រមគំ-និតនឹងអាជួន យាយផាន់បានឲ្យគេក្លែងសំបុត្រមួយផ្ញើមកចៅថា ខ្ញុំឈឺធ្ងន់ហើយសូមឲ្យចៅមកនាប់ ៗ ចៅបានដំណឹងម្តាយឈឺ ក៏លាប្តីមកជាមួយកំលៀងនោះ ៗ

ទៅដល់ដើមខាលឃើញម្តាយជា រៀបចំការនាងនឹងម៉ឺនជួនទៅវិញ នាងចៅបានប្រកែកនឹងម្តាយតែម្តាយមិនស្តាប់ ចៅបានសរសេរសំបុត្រទៅខ្ញុំឲ្យចាប់ប្រញាប់មក ៗ ខ្ញុំដឹងរឿងក៏បានទូលលាព្រះរាមា ហើយនាំពេជមកជាមួយផង ខ្ញុំទៅដល់ផ្ទះដើមខាល ឃើញគេកំពុងរៀបការ ខ្ញុំបានស្និទ្ធស្នាលជាអស្ចារ្យជាមួយចៅនៅមុខភ្ញៀវ ៗ ឃើញដូច្នេះយាយផាន់អាជួនខឹងប្រើឲ្យចាប់ខ្ញុំយកទៅសម្លាប់ ៗ

ចៅដឹងថាខ្ញុំត្រូវគេសម្លាប់ហើយ ក៏បានឲ្យនារីកកាំ-

បិតស្លាហើយក៏នាំនាងនោះ គេចរត់ទៅផ្នូរខ្មោចទុម ។ ជួប ក្មេងឃ្វាលគោ ទាវដោះបិញ្ចៀនឲ្យក្មេង ពឹងឲ្យទៅប្រៀង នៅផ្ទះរៀបការថា៖ « អស់លោកតាស់ទុំស្លាប់ខ្ញុំណា លោកការនេះណា ទាវទៅក្ស័យ មូលមួយនឹងគ្នាជាបីប្រាណ ស្លាប់ក្នុងស្មសាន្ត តាំងពីថ្ងៃ ដែលលោកយកទុមទៅប្រល័យ ស្លាប់តែហោងហើមក្រោមដើមពោធិ» ។

ដល់ផ្នូរទុម ទាវស្រាយផាហ៊ុំទុមហើយយកព្រះសង្ហារចាក់ លើខ្មោចទុម ។ នាងក៏បានចាក់កដេកស្លាប់ជិតទុមទៅ ឯនោក៏បានសម្លាប់ខ្លួនទៅជាមួយដែរ ។

ឯចំណែកក្មេងឃ្វាលគោក៏បានមកប្រៀងប្រាប់អ្នកការៗ នោះឡូស្តីជេរគ្នា ។ ចំណែកពេជវិញ ឃើញគេសម្លាប់ទុម ហើយទាវនឹងនោះទៅសម្លាប់ខ្លួនដូច្នេះ ក៏រត់ទៅទូលព្រះរាមា នៅលង្វែកវិញ ។ ព្រះរាមាទ្រង់ក្រោធក៏បានលើកទាហានមក ត្បូងឃ្មុំ ហើយបានកាប់សម្លាប់អរជូនដូនជាន់ ព្រមទាំង ដាក់ប្រជាជនទៅស្រុកនោះថា «អ្នកងារ» ។

រឿងនេះមានប្រយោជន៍សំខាន់ណាស់ អាចឲ្យយើងឆ្លុះមើលរបៀបគ្រប់គ្រងនៅជំនាន់នោះ នឹងគំនិតអ្នកស្រុក ។ យាយចាស់ជាម្ដាយ ប្រើអំណាចស្រឡាញ់បុណ្យហើយទុកដាក់កូនទៅបង្ខំចិត្ត ដូចជាមានពាក្យថា «ទំមិនដែលធំជាងនាឡិ» ។ ទំនៀមទម្លាប់នេះ បានធ្វើឲ្យស្រីខ្លះ ទទួលយកប្រុស (ប្ដី) ដែលខ្លួនមិនស្រឡាញ់ ហើយខ្លះទៀតក៏ទទឹងមិនព្រមយកបានតែប្ដូរសម្លាប់ខ្លួនក៏សឹងមាន ។ រឿងទុំទាវនេះជាភស្តុតាងស្រាប់ ។

ទុំនឹងទាវស្រឡាញ់គ្នាជាសុខ កុំតែមានយាយចាស់នឹងឥតជូនទៅព្រាត់ ។

ពេជជាកល្យាណមិត្ត ដែលយើងគួរយកតាំងបាន ។

អាកប្បកិរិយាអរជូន សឲ្យឃើញថា នាម៉ឺនមន្ត្រីជំនាន់នោះ មានគំនិតឃោរឃៅមានអំណាចដូចស្ដេចត្រាញ់ចាប់កាប់ប្រជាជនមានពង្រាត់ទាវនឹងទុំជាដើម ។

ស្ត្រីទាវឯកនេះ បានបង្ហាញឲ្យយើងឃើញជាក់ជា

អំណាចលើផ្នែកស្រាវជ្រាវរកស្រីមកថ្វាយជាដើម ។ ស្ដេចយាងទៅណា ដូចជាទៅត្បូងឃ្មុំត្រូវមាននាម៉ឺនស្រីស្នំច្រៀងសកកាទំហែតាមជានិច្ច ។ ទៅដល់កំពង់ត្បូងឃ្មុំទៀត ក៏មានកេណ្ឌប្រជាជនឲ្យត្រាយផ្លូវទៅដើរខាល ។ របៀបកាត់ក្ដីទៀត ក៏គ្មានច្បាប់ឯណាជាធំក្រៅពីការវិនិច្ឆ័យផ្ទាល់របស់ព្រះកមា ដូចជាមានកាត់ទោសគ្រួសារអោរដូនហើយទាំងទម្លាក់ប្រជាជនឲ្យទៅជាអ្នកងារជាដើម ។

## រឿង ទាវ-ឯក របស់លោក វិបុលសេដា នូ-កាន

ក្នុងការប្រឡងអក្សរសាស្ត្រ តាមព្រះរាជប្រកាស ១៩៤២ លោកនូ-កន ជាកវីអក្សរសាស្ត្រខ្មែរយើង បានយករឿង ទាវ-ឯកមកលើកជាថ្មី ។ សៀវភៅទាវ-ឯក របស់លោកនូ-កន បានជាប់លេខបានរង្វាន់ ។ តាំងពីនោះ

មកសៀវភៅ ទាវ-ឯក នោះ បានបោះផ្សាយលក់ឲ្យប្រជាជន មើលជាច្រើនលើក ។ សៀវភៅនេះមានចំនួនប្រាំខ្សែ ។ សាស្ត្រាចារ្យខ្លះនៅវិទ្យាល័យ បានយកសៀវភៅ ទាវ-ឯក លោក នូ-កន ទៅបង្ហាត់បង្រៀនសិស្ស ។ តាមសង្កេតមើលទៅប្រហែលគេនិយមទុករឿង ទាវ-ឯក លោក នូ-កន ជារឿងពិតថាជាអក្សរសាស្ត្រពុកណា បានជាគេយកសៀវភៅនេះទៅបង្រៀន ។

ទាវ-ឯករបស់លោក នូ-កន ខុសឆ្ងាយពីរឿងដែលបានចងតាក្បួនស្ត្រាស្លឹករឹត ហើយដែលយើងបានបង្រួមរឿងខាងលើរួចហើយ ។ ដោយផ្លូវរឿងបាត់ច្រើនដូច្នេះ យើងខ្ញុំបានសួរបញ្ជាក់ថា: ហេតុអ្វីបានជារឿង ទាវ-ឯក ឃ្លាតឆ្ងាយពីសាស្ត្រាស្លឹករឹត, លោក នូ-កន បានឲ្យយោបល់ក្នុងការម្តកថាថា:

„ដែលខ្ញុំតាំងរឿងនេះយកមកតែង គឺខ្ញុំយកតាមសំដី

អ្នកចម្រៀងក្នុងវាំង កាលរាជព្រះករុណានរោត្តមគង់ព្រះ
ជន្មនៅឡើយ ម្ចាស់ចម្រៀងថ្វាយព្រះសណ្តាប់ ខ្ញុំស្តាប់ចាំ
ម្ចាស់ ឃើញថា សេចក្តីចម្រៀងមានបញ្ហាល្អិតល្អ ។

ហេតុនេះខ្ញុំសូមឲ្យលោកអ្នកអានរឿងទាំងឡាយ កុំ
ចូលចិត្តតែរឿងណាដែលពិតប្រាកដទើបចូលចិត្តអាន បើ
រឿងណាមិនពិតមិនចូលចិត្តស្តាប់ មិនចង់អាន , មិនចង់ឮ
តទៅ , សេចក្តីដែលគិតដូច្នេះ នាំឲ្យមនុស្សយើងរឹតតែល្ងង់
ខ្លៅទៅទៀត លោកអ្នកអានទាំងឡាយគិតមើលចុះ ! ។
រឿងប្រលោមលោកខាងប្រទេសអឺរ៉ុប មានឈ្មោះឡាហ្វុង
តែនថា: ដើមស្វាយនឹងដើមបបុស ឬ សត្វរ៉ៃ ទីងស្រ-
មោចៈចេះទិញលាយគ្នា ។ រឿងខាងប្រទេសអាស៊ីមានឈ្មោះ
ជេញជ័យអ្នកប្រាជ្ញ ឧបមាជ័យមេរគជាដើម បុរាណ
លោកតែងទុកជាប្រស្នា ឲ្យមនុស្សឆ្លាតចេះដឹងរឿងទាំង
នោះ ថាជារឿងពិតដែរឬទេ ?

ខ្ញុំសុំពន្យល់បន្តិចទៅទៀត សូម្បីតែគម្ពីរក្នុងព្រះពុទ្ធ-សាសនាក៏មានអ្នកប្រាជ្ញតែងរៀងជាបាលីសុទ្ធដូចគ្នា ដូចយ៉ាងគម្ពីរមង្គលត្ថទីបនី មាននិយាយពីម្រឹគបក្សាវះនិយាយគ្នា គម្ពីរសារត្ថសង្គហៈ មាននិយាយពីវាស់ទំហំព្រះអាទិត្យ ព្រះចន្ទនឹងផ្កាយជាដើម គម្ពីរមហាវង្សមាននិយាយពីព្រះពុទ្ធជាម្ចាស់ទ្រង់ធ្វើបាដិហារិយ៍បណ្ដេញយក្ខយកកោះលង្កា តើអស់លោកអ្នកយល់ឃើញថា គម្ពីរទាំងអស់នេះ ត្រឹមត្រូវណាស់ទៅឬ ? យើងអ្នកអានគិតត្រង់មែន និងមិនមែននោះទេ គឺត្រូវគិតដល់បញ្ហាសមហេតុសមផល បានជាប្រ-យោជន៍ឬមិនជាប្រយោជន៍តែប៉ុណ្ណោះ» ។

ការម្កកថាខាងលើនេះ បានបំភ្លឺយើងឲ្យដឹងថា គម្ពីរព្រះពុទ្ធសាសនាទាំងប៉ុន្មាន ច្រើនអ្នកប្រាជ្ញលើកជាប្រស្នាដូច្នេះ យើងអ្នកអានត្រូវគិតបញ្ហាមានសមហេតុសមផលបានជាប្រយោជន៍ឬមិនជាប្រយោជន៍ប៉ុណ្ណោះ តែមិនត្រូវជឿ

ដោយឥតការតាំងហារណា ឥតសង្ស័យ ។ ត្រង់ចំណុចនេះ យើងស្របពេញទីទឹងលោកគ្រូ-គន តែយើងសូមជូនយោបល់បន្តិចអំពីចម្រៀង ។ ចម្រៀងក្នុងរាំងក៏ដូចជាចម្រៀងរឿងជាប៉ុធម្មតា អ្នកច្រៀងខ្មែរយើងច្រើនតែច្រៀងបំផ្លើសពីរឿងដើម ដោយមានចេតនាលើកតម្រូវអ្នកស្តាប់តែប៉ុណ្ណោះ ។ អ្នកដែលបានស្តាប់ចម្រៀងនោះក៏ច្រើនតែយកមកច្រៀងបំផ្លើសត ៗ មកទៀត ជួនកាលក្លាយខុសឆ្ងាយពីរឿងដើមហួសពេកក៏សឹងមាន ។ ដូច្នេះ យើងមិនអាចថាចម្រៀងមានបញ្ហាល្អិតល្អពិតជាងរឿងដើមឡើយ ។ អ្នកចម្រៀងយើង មិនចេះគោរពពាក្យពេចន៍សេចក្តីអ្នកនិពន្ធប៉ុន្មានទេ គេច្រើនប្រើវោហារពាក្យឃ្លាងរបស់គេ ហើយផ្សំក្រៅឡើសេចក្តីអ្នកនិពន្ធទៅវិញ ។

ម្យ៉ាងទៀត រឿងទាវ-ឯកជារឿងពិត មិនមែនដូចរឿងគាព្រ្កាល្បែងឬច្បាប់ក្រម ច្បាប់ប្រុសស្រី ។ល។ ដែលអ្នកកវីតែងឡើង ដើម្បីយកមកដឹកពត់ចិត្តប្រជាជន ។ ដូច្នេះអ្នក

និពន្ធរឿងពិតជាក់ស្តែង ត្រូវគោរពការពិត ហើយត្រូវទម្លាក់គំនិតផ្ទាល់ខ្លួនចោលឲ្យអស់ ៗ ដើម្បីសរសេររឿងតាវឯកកុំឲ្យឃ្លាតឆ្ងាយពីរឿងជាក់ស្តែង យើងត្រូវដាក់ខ្លួនទៅសតវត្សទី ១៩ ហើយស្រាវជ្រាវ រកឯកសារមើល ការរស់នៅនិងគំនិតសង្គមខ្មែរយើងក្នុងជំនាន់នោះ ព្រមទាំងឲ្យដឹងអាកប្បកិរិយាចុមនឹងតាវឲ្យជាក់លាក់ផង ៗ តាមសេចក្តីនេះយើងឃើញថាតឹងណាស់ដែរ ព្រោះយើងគ្មានឯកសារប្រវត្តិសាស្ត្រឲ្យជាក់លាក់ផង ៗ

ក្រោយដែលបានមើលរឿងតាវឯក ទាំងពីររឿងសាស្ត្រាស៊ឹករឹតនឹងរឿងរៀបរៀងដោយលោកនូ-កន ខ្ញុំយល់ឃើញថាសាស្ត្រាស៊ឹករឹតនិយាយរ៉ាវរឿងសម ហើយគួរណាស់តែយើងយករឿងនោះជាគោល សម្រាប់យើងឆ្លុះមើលសង្គមខ្មែរយើងនៅសម័យបុរាណ ។

ឯចំណែករឿងតាវឯកនៃលោកនូ-កន បានបញ្ចាំងយោបល់ផ្ទាល់របស់លោក នូ-កន នេះឯង ៗ ក្នុងចម្រៀង

ដែលខុបច្រៀងថ្វាយព្រះពរ យើងមិនសង្ស័យថា ខុមហាន ប្រាប់ព្រះមហាក្សត្រដូច្នេះទេ នៅសតវត្សទី១៩ ។ ចម្រៀងនេះទៀត គឺវែងហួសហេតុពិតអស់ខ្សែ ៣ ។

ចំពោះរឿងនេះ គួរណាស់តែសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរនៅវិទ្យាល័យ អនុវិទ្យាល័យ ឬ នៅសាលាបាលីជាន់ខ្ពស់ ឬវត្តក្តី ពិនិត្យរឿងនេះឲ្យមែនទែន ព្រោះរឿង ទាវ-ឯក ត្រូវយកទៅបង្រៀនជាជាប់ខាតក្នុងថ្នាក់ទី ៤ ឬ ៥ ទំនើបៗ

បើតាមយោបល់យើងៗ សូមឲ្យរៀនតាមសាស្ត្រាស្លឹករឹតវិញបានសមជាង ឬ ក៏ត្រូវតែចម្លងរឿងពីសាស្ត្រាស្លឹករឹតបោះផ្សាយចែកសិស្សនិងគ្រូដែលត្រូវរៀនឲ្យមានគ្រប់គ្រាន់ឡើងៗ

## ២- អក្សរសាស្ត្រប្រជាជន

អក្សរសាស្ត្រប្រជាជន គឺរឿងព្រេងដែលប្រជាជនបាននិយាយតៗគ្នា រឿងរហូតមកពីមាត់មួយទៅមាត់មួយ ។ រឿងព្រេងច្រើនជារឿងខ្លីៗ ។ មានតែរឿងធេ្ញជ័យ; អាឡេវដែលវែងបន្តិច ។ រឿងព្រេងជារឿងជឿនលឿន

សម្រាប់ជាសំប្រជាជនឲ្យភ្ញាក់រលឹក ។ ហេតុនេះហើយបានជាវណ្ណៈខ្ញាំងពូកែសម័យនោះ មិនបានយកចិត្តទុកដាក់ចង់ជាសាស្ត្រាស្លឹករឹត ទុកឲ្យប្រជាជនរៀនទឹងពិចារណាគ្រប់គ្នាឡើយ ។ ផ្ទុយទៅវិញ គេច្រើនលើករឿងផ្តេសផ្តាសបន្ទំ ដូចជាអាដ័យមោរតហើយឲ្យយោបល់ថា រឿងព្រេងទាំងនោះមិនសមរម្យថោកទាបសម្រាប់តែ «អាមនុស្សថោកទាប មានពូជអម្បូរទុគ៌ត» សម្រាប់តែវង់អាយ៉ៃយកទៅឡកកំផុកកំផ្លែងលេង ។ មានខ្លះទៀតថា រឿងទាំងនេះជារឿងឆ្គួតគ្មានបានការអ្វីទេ ។ បើពិនិត្យសើរ ១ យើងអាចជឿទៅតាមយោបល់ខាងលើនេះទាំងអស់ ។

រឿងព្រេងជារឿងប្រជាជន មានអត្ថរសខ្លឹមសារ ជំពាស់ពេញទីទឹងការអប់រំអយុត្តិធម៌ នៃសង្គមខ្មែរនៅសម័យនោះ ។ ក្នុងរឿងព្រេងទាំងនោះ គេបានលើកអ្នកតួឯកឬអ្នកគំរូតែជនសាមញ្ញកូនប្រជាជនពិតៗ គេមិនបានអវណ្ណកអណ្តាន់ទៅប្រចុបប្រថែងរើសកូនទេវតាចុះពីឋានលើ ដូចក្នុង

សាស្ត្រាល្បែងឡើយ ។ រឿងព្រេងច្រើននិយាយពីការទាក់ទងមនុស្សពិតៗក្នុងសង្គមខ្មែរនិងសង្គមជាតិដទៃ មានជាតិចិន,ជ្វា,ជាដើម ដែលមកកេស៊ីធ្វើសំពៅ ជំនួញនៅស្រុកខ្មែរយើង ។

## ក)- រឿងព្រេងបានប្រឆាំងពេញទី និងជំនឿការបន់ស្រន់ហោមានអ្នកតា-

នៅក្នុងរឿង «អាពោរចិត្តជា» មានមន្ត្រីតូចម្នាក់បន់បានឡើងធ្វើចៅហ្វាយស្រុក ព្រួយចិត្តដោយគ្មានលុយយកទៅថ្វាយស្តេចវិញបុណ្យនោះ ។ នៅពេលយប់មួយមន្ត្រីនេះបាននិយាយប្រាប់ប្រពន្ធឲ្យជួយគិតរកប្រាក់ទៅទិញងារជាសក្តិចៅហ្វាយស្រុក ។ ប្រពន្ធក៏បានឆ្លើយថា «យើងតុបតូបបន់ព្រះសុំឲ្យបានលុយ» ។ អាពោរចិត្តជាដែលយប់នោះទៅលបលួចមន្ត្រីនោះ ឃើញមន្ត្រីតុបតូបបន់ព្រះសុំលុយដូច្នោះ ក៏អាណិតយកប្រាក់មកផ្តល់ឲ្យក្នុងយប់នោះទៅ ។ ព្រឹកឡើងមន្ត្រីក៏បានប្រាក់យកទៅទិញងារ

ទៀនសក្តិជាចៅហ្វាយស្រុក ។ល។

ក្នុងរឿង «មាយាស្រី(១)» មានស្រីម្នាក់មិនស្រឡាញ់ប្តីខ្លួន ព្រោះបានស្រឡាញ់ប្រុសផ្សេងទៀត ។ មានថ្ងៃមួយស្រីនោះដើរចូលព្រៃបន់អ្នកតា ៗ ជួនជាពេលនោះប្តីនាងទៅរកដំរុងនៅព្រៃនោះដែរ បានឃើញប្រពន្ធដើរទៅបៀត ក៏លបពួនក្រោយជអ្នកតា ហើយចាំពិនិត្យមើលប្រពន្ធ ៗ ប្រពន្ធនោះបានទៅបន់អ្នកតាសូមឲ្យកាច់កប្តីឲ្យស្លាប់ទៅ ។ បុរសជាប្តីពួននៅក្រោយជុំអ្នកតា ធ្វើជា «អ្នកតា» បានឆ្លើយតបមកវិញប្រាប់ឲ្យស្ត្រីនោះស្ងោរទានឲ្យប្តីពេលល្ងាច ហើយប្តីនោះមុខជាពុករោះស្លាប់មិនខាន ។ល។

រឿងពីរខាងលើនេះ ដែលយើងបានដកស្រង់នេះជាកសិណពន្យល់យើងជាក់ថា រឿងព្រេងខ្មែរមានគេ [illegible] ខ្លួនយើងដោយឧទាហរណ៍សល់ល្អិត កុំឲ្យគំនិតគន្លងជឿង ទៀអ្នកតាជួយឲ្យគេសោះ ។

(១) មើលសៀវភៅ អត្ថាធិប្បាយរឿងព្រេងខ្មែរ

១) រឿងព្រេងប្រឆាំងនឹងជំនឿមន្តអាគម- ក្នុងរឿង «សិស្សទឹងគ្រូ» មាននិទានព្រះសង្ឃមួយព្រះអង្គធ្វើជាមេវត្តផង ។ ព្រះសង្ឃនេះត្រូវកូនសិស្សបោក លែងឲ្យវារែកអំបិល ឲ្យឆាន់បាយក្រោយវាវិញ ។ ព្រះសង្ឃនោះខ្ញាល់ ក៏វាយកូនសិស្សៗបបួលគ្នាគេចរត់អស់ ។ ឃើញកូនសិស្សទៅអស់ លោកគ្រូក៏តាំងរៀនមន្តអាគម ។ ក្មេងឃើញដូច្នេះក៏បបួលគ្នាត្រឡប់មកវត្តវិញ ។ វាបញ្ឆោតលោកថា: «លោកគ្រូចេះមន្តអាគមពូកែ» ។ លោកគ្រូឆោតស្មានថាក្មេងត្រូវមន្តអាគមរបស់ខ្លួនបានត្រឡប់មកវិញ ក៏រឹតតែជឿនូវមន្តអាគមថែមទៀត ។ ក្មេងវាបញ្ឆោតថា លោកគ្រូពូកែ ចេះបំបាំងគ្មាននរណាមើលឃើញ ។ ថ្ងៃមួយឧបាសកនិមន្តលោកទៅឆាន់ក្មេងបានប្រាប់កុំឲ្យលោកគ្រូស្លៀកស្បង់ គ្រងតែចីពរបានហើយ ព្រោះលោកគ្រូចេះបំបាំងហើយ ។ លោកគ្រូក៏ធ្វើតាម ។ លុះទៅដល់ផ្ទះឧបាសក ពេលឆាន់លោកគ្រូវាយភ្លែនក៏បញ្ចេញកេរ្តិ៍ខ្មាសកណ្តាលវាល ឧបាសកកេះគ្នាសើច

លាន់ ៗ លោកគ្រូអៀនខ្មាស់ឈប់លែងដាន់ ។

រឿងនេះហើយនឹងនៅមានរឿងច្រើនទៀត បានពន្យល់ប្រជាជនថាកុំឲ្យជឿមន្តអាគមប៉ះពាល់ឲ្យសោះ ។

## គ) រឿងព្រេងប្រឆាំងនឹងរបបសង្គមផ្ដាច់ឪពុកក្មេក–

យើងបានដឹងគ្រប់គ្នាថា ពិតមែនតែគេ «ទុកស្រីដូចស្ពាន់ ប្រុសដូចពេជ្រ» ឪពុកម្ដាយខាងស្រីមានអំណាចសម្បើមណាស់ ៗ គាត់មិនគ្រាន់តែបង្ខំកូនស្រីគាត់ឲ្យយកប្រុសដែលគ្នាមិនស្គាល់ទេ គាត់មានឥទ្ធិពលសំឡុតកូនប្រសាប្រុសមកផ្ដាប់គាត់ឲ្យធ្វើតាមបំណងរបស់គាត់ទាំងអស់ ។ ចំពោះរឿងនេះ មានរឿង «ឪពុករើសកូនប្រសា» បានបង្ហាញគំនិតពុតអាក្រក់នៃឪពុកម្ដាយក្មេក ។ ឪពុកកូនស្រីបានដាក់កំរិតឲ្យកូនប្រុសត្រាំធ្វើការ ដែលគាត់មានបំណងយកលះប្រើចាំងប៉ុន្មាន ដូចជាមានក្ដារកុំឈប់ស៊ីបាយ បើកាលណាខ្ញុំពុំមិនស្រែក បើកូនប្រសាឲ្យធ្វើឆ្ពោះទៅរកអណ្ដើក ។ លុះកូនប្រសាធ្លាក់លប់ស៊ីបកលល្បិចដីមុន គឺបានធ្វើយកបង់...

ឃោរឃៅ បង្អត់ឲ្យឪពុកក្មេកវិញ បណ្ដោយឪពុកក្មេកទៅ រកអណ្ដើក ធ្វើឲ្យឪពុកក្មេកធ្លាក់ពីលើស្ពាន ។ល។ ដល់គំនិតកំសុខចិត្តឲ្យកូនស្រី ។

រឿងនេះប្រឆាំងពេញទី នឹងរបបឪពុកម្ដាយក្មេកធ្វើបាប កូនប្រសារទៅផ្គាប់ខ្លួន មានឲ្យគ្នាលុតលុបក្រាប វត់មុខពេទះ គោទ្រូះផង ។ល។

ដើម្បីឲ្យដឹងច្បាស់ស្រួលស្ដាប់រឿងព្រេង សូមអ្នកអាន មើលរឿងទាំងនោះ ។ យើងស្ដាយជាខ្លាំង ដោយយើងមិន អាចបង្រួមគ្រប់រឿងបានព្រោះក្នុងអត្ថបទ „អក្សរសាស្ត្រ ខ្មែរ„ នេះ យើងគ្រាន់តែវែកញែកមើលគំនិតអក្សរសាស្ត្រ តែប៉ុណ្ណោះ ។

៥) រឿងអាឡេវ- „អាឡេវ„ ជារឿងព្រេងដែលប្រជា ជនបានដឹងស្ទើរគ្រប់គ្នា ។ ពួកក្រុមអាយ៉ៃបានយករឿងនេះ ច្រៀងលេង ហើយមានទាំងថតដាក់ថាសម៉ាស៊ីនច្រៀង ផង ។ អាឡេវជាកូនប្រជាជនម្នាក់ ។ មួយជីវិតវា គឺប្រ

ទាំងនឹងទំនៀមទម្លាប់សង្គមក្នុងសម័យវា ។

ធម្មតាគេទូន្មានកូនប្រុសតែទុកទំនៀមទម្លាប់ចាស់ទុំជា ត្រឹមត្រូវ តែអាឡេវមិនបានស្របតាមពាក្យទូន្មាននោះទេ ។ វាបានបង្ហាត់ឪវាឲ្យហាត់រត់ ៗ បន្ទាប់មកចង់ស៊ីទំ អាឡេវ បានរៀបចំផ្សំផ្គុំផ្ទះម៉ែវាទៅវិញ ។ ចំណែកព្រះសង្ឃដែលមាន ទំនៀមជឿ ប្រើនតម្កើងជាអ្នកប្រាជ្ញបណ្ឌិតសុចរិតយុត្តិធម៌ ត្រឹមត្រូវគិតតែសម្បត្តិ «ស្ងួតទិញខ» អាឡេវបានលើក គូព្រះសង្ឃគង់នៅវត្តមួយ ឲ្យយើងឃើញថយទៅវិញ ។ ព្រះសង្ឃមួយអង្គនោះបានពឹងអាឡេវរកស្រីកញ្ញាឲ្យទៅវិញ ។ តែអាឡេវធ្លាក់វៃបាននាំសង្ឃអង្គនោះទៅដល់ទីអាចក ។ ខ្លាចបែកការហើយមានទោសបារាជិក ព្រះសង្ឃអង្គនោះក៏ មានភ័យស្លុតប្រញាប់ដែលបានពីក្តីព្រះហ៊ុំនៃទុក្ខាសក ទុក្ខាសិកា ឲ្យទៅអាឡេវដល់មួយបាត្រ ។

ជាមួយសង្គមនោះ អាឡេវ ដើរផ្លូវលើឈ្មោះបោះបាន បកសំពៅ ៥០០ ពីនោះ ។

ទៅកាន់ទីក្រុងនៅបំរើសេដ្ឋី អាឡេវបានត្រូវសេដ្ឋីលើកកូនស្រីឲ្យធ្វើជាប្រពន្ធ ។ អាឡេវនៅតែមានចរិតប្រជាជនដដែលមិនបានដោះដោយធនធានទេ ។ វាទៅជួបអស់នាម៉ឺនមន្ត្រីនៅព្រះពន្ធមុខវាំង កាន់ចរិតប្រជាជនធម្មតា ។លុះឃើញកូនស្រីសេដ្ឋី ដែលត្រូវជាប្រពន្ធវាដើរទៅ វាក៏និយាយថាវាអាចប្រើកូនស្រីសេដ្ឋីឲ្យយកហិបស្លាម្លូជូនវា ។ នាម៉ឺនមាក់ងាយវាមិនជឿក៏បន្ទុះបង្អាប់វា ។ អាឡេវបានបបួលភ្នាល់ នាម៉ឺនយល់ព្រម ។ លុះដល់កូនស្រីទៅដល់ក៏យកម្លូស្លាបារីឲ្យវាមែន ។ អាឡេវភ្នាល់ឈ្នះនាម៉ឺនទាំងអស់បានទ្រព្យជាច្រើន ។

នាទីអាឡេវមានតែក្នុងសង្គមគ្រួសារ, វត្តលោកសង្ឃ, ចោរ,សេដ្ឋី,នាម៉ឺនតែប៉ុណ្ណោះ ។ យើងបានសង្កេតឃើញថាគង់តែនាម៉ឺនមានអំណាចអាងយ៉ាងពស្ត្រ ក្នុងសម័យនោះដូចមានអ-ជ្ញូនក្នុងរឿងចោរ-ឯកជាដើម ក៏អាឡេវកូនប្រជាជនមិនព្រមចុះចាញ់ហើយបានជ័យជំនះទៅវិញ ។

ច) រឿងធនញ្ជ័យ – រឿងព្រេងនេះល្បីសុះសាយ ។ ប្រជាជនបានដឹងស្ទើរគ្រប់គ្នា ហើយច្រើនដកស្រង់ចំពូកខ្លះយកទៅនិយាយកំសាន្ត ។ តែដូចរឿងព្រេងដទៃទាំងពួង រឿងធនញ្ជ័យមិនបានបោះពុម្ពផ្សាយឲ្យប្រជាជនមើលគ្រប់គ្នាទេ ។ សិស្សខ្មែរនៅវិទ្យាល័យ មិនអាចរកសៀវភៅរឿងព្រេងអក្សរសាស្ត្រខ្មែរមើលរៀនគ្រប់គ្នាឡើយ ។

រឿងធនញ្ជ័យមានអត្ថរសខ្លឹមសារល្អណាស់ ។ រឿងព្រេងនេះជាស្នាដៃប្រជាជនខ្មែរយើង នៅសម័យសក្តិភូមិ ។ យើងសូមដកស្រង់ចំពូកខ្លះ ហើយនិយាយកាត់ ។ ដូចត-ទៅនេះ ៖

...ធនញ្ជ័យជាកូនអ្នកស្រែ ។ ក៏ទៅស្នាក់នៅលេងផ្ទះមហាសេដ្ឋី ។ ថ្ងៃមួយក៏មានអាយុប្រហែល ៧ ឆ្នាំ ប្រពន្ធសេដ្ឋីស្ដីរើសគ្រលប់ឲ្យ ហើយសន្យាថាឲ្យអំបុកគាំ ។ ធនញ្ជ័យបានរើសគ្រលរួចក៏បានទារអំបុក ។ ប្រពន្ធសេដ្ឋីឲ្យអំបុក តែធនញ្ជ័យនៅក្រាញយំថាតិចណាស់ ។

សេដ្ឋីមកខាន់ស្លរដឹងរឿងហេតុក៏បែកអំបុកជាពីរគំនរ ហើយប្រើឲ្យធ្មេញជ័យរើសគំនរអំបុកណាច្រើនយកទៅចុះ ។ ទីងទីងតាញ់ពោកសេដ្ឋី ធ្មេញជ័យបានឲ្យម្ដាយគាត់ យកទៅលក់ធ្វើជាខ្ញុំមហាសេដ្ឋីៗ ធ្មេញជ័យបានទុកសេដ្ឋីជាអ្នកពូកែតែយកចំណេញមួយធំជាសត្រូវរបស់គាត់ ដូច្នេះក្នុងកំឡុងគាត់ធ្វើខ្ញុំសេដ្ឋី គាត់បានធ្វើល្បិចកលបំផ្លាញកិត្តិនាមឲ្យអប្បយសទីទំលាយផងជានទៀត ដូចមានរឿងរើសគាថមសេះដាក់ថង់យាម, បាំចំការឲ្យគោស៊ីដំណាំអស់ៗលៗ សេដ្ឋីពាល់ដំរិះក៏បានយកធ្មេញជ័យទៅថ្វាយស្ដេច ។

បានខ្លាស់ថ្មី ធ្មេញជ័យមិនដើរខ្សែក្រោមទេ គាត់លេងល្បែងលើជានិច្ច ។ • គាត់ករយ៉ាងស្រស់ថ្វាយស្ដេច អំពីក្បួនករ ។ ស្ដេចបានត្រិះរិះគ្រប់គល់ល្បិច ដល់មាន់,ដល់ក្របី, ទៅក្រសាលព្រៃដំរិះសេះ, មុចទឹកថ្វាយពំនាន់ស្ដេចៗលៗ ដើម្បីយកទោសធ្មេញជ័យតែធ្មេញជ័យដោះស្រាយឈ្នះរួចខ្លួនជានិច្ច ។ ក្នុងដំណាក់ជាទីលំនៅ អស់

នាងស្រីស្នំ ធ្មេញជ័យត្រូវស្ដេចប្រើទៅបោសព្រាស ។ គាត់បានរឹងទឹងអស់នាងដើរលើក្បាល ក៏ជេរថា ៖ «មេពោរ រក់ស៊ីតែខ្ទឹងក្តិត» ។ អស់នាងប្ដឹងឲ្យចាប់ទោសធ្មេញជ័យ ។ បានឆ្លើយថាដេរពីងពាងពន្លសំបុកវិញទេ ។ នៅពេលស្ដេចប្រើស្រីស្នំឲ្យទៅដុះដាក់ផ្ទះធ្មេញជ័យ ១ ដេញកាយ ។ ត្រូវដាប់ចោទទៀត តែធ្មេញជ័យបានឆ្លើយថា៖ «បានដាកាយព្រោះស្រីចាំងនោះនោម» ។ ព្រោជាធ្មេញជ័យបានធ្វើឲ្យស្ដេចមានបារម្ភជាច្រើន ម្ល៉ោះហើយក៏ប្រើ៖បាយឲ្យធ្មេញជ័យទៅខេត្តក្រៅ ។ តមកធ្មេញជ័យត្រូវដាប់ទោស ស្ដេចឲ្យយកទៅសម្លាប់ ។

នៅលើទូកពេជឃាតនាំទៅសម្លាប់ ធ្មេញជ័យបានដើរនយោបាយបង្កើតចម្រៀង «ធ្មេញជ័យធ្លាក់ទឹក ! ហៃហើ» ។ លុះធ្មេញជ័យលោតមុជទឹកគេចទៅ ។ អ្នកចែវទូកមួយក្រុមស្រែកថា៖ «ធ្មេញជ័យធ្លាក់ទឹក» ពួកមួយក្រុមទៀតស្រែកបន្ទរឡើងថា៖ «ហៃហើ» ។

ក្រោយមកធ្មេញជ័យបានទៅបួសជាភិក្ខុ ។ បន្ទាប់មកធ្មេញជ័យ បានដោះប្រស្នាឈ្នះអ្នកប្រាជ្ញចិនល្បីល្បាញ ។ ធ្មេញជ័យ បានត្រូវទៅស្រុកចិន ។ ស្តេចក្រុងចិនបានចាប់គាត់ដាក់គុក ។ ដើម្បីឲ្យរួចពីគុកធ្មេញជ័យ បានធ្វើឯកបង្កើរខ្ទង់ បន្ទីស្ទូរសព្ទធ្វើឲ្យស្តេចចិនដេកមិនលក់ ជាមូលហេតុនាំឲ្យធ្មេញជ័យមកស្រុកខ្មែរវិញ ។

នៅពេលឈឺខ្លាំងជិតស្លាប់ ស្តេចទៅសួរធ្មេញជ័យ ។ បានខ្សឹបផ្តាំថា: «ស៊ីត្រីព្រលក់កុំចោលស្រការ បើស៊ីត្រីប្រាកុំចោលស្រកី ឲ្យស្ងួតត្រីប្រាទីងម្ហូរសណ្តាន់ » ។ លុះស្តេចត្រឡប់ទៅវាំងវិញ អស់នាម៉ឺនបានសួរស្តេច តើធ្មេញជ័យបានផ្តាំដូចម្តេចខ្លះ ស្តេចបានឆ្លើយប្រាប់តាមធ្មេញជ័យប្រាប់ទាំងអស់ ។ អស់នាម៉ឺនជឿជាក់ល់មិនគិតស្មានថាធ្មេញជ័យជាអ្នកប្រាជ្ញនិយាយដូច្នោះ ក៏ត្រូវលនិយាយថា «យើងទុកចិត្តថាស្តេចជាៗមិនបានទេ បានជាស្រុកខ្មែរយើងខ្ចាចស្តេចលុកជន្ល៍ន់ដូច្នេះ» ។

មុននឹងស្លាប់ធ្មេញជ័យ បានផ្តាំឲ្យគេស្រះបន្ទាលើផ្នូរគាត់ ។

សៀវភៅធ្មេញជ័យ — សព្វថ្ងៃយើងក្រសៀវភៅរឿងនេះណាស់ ។ គេឃើញមានចុះរឿងនេះក្នុងទស្សនាវដ្តីកម្ពុជ-សុរិយាជាពាក្យរាយដែរ តែចំនួនសៀវភៅតិចពេក ។

ម្យ៉ាងទៀត យើងឃើញលោក មាស-សាម បានមានគំនិតបោះពុម្ពរឿងធ្មេញជ័យខ្សែទី ១ ជាពាក្យកាព្យដែលជាស្នាដៃកវីបណ្ឌិតម្នាក់មិនស្គាល់ឈ្មោះ បានរៀបរៀងនៅ ព.ស ២៤៩៦ ។ យើងស្តាយជាខ្លាំងដោយមិនទាន់ឃើញខ្សែទី ២ តទៅទៀត ។ យើងសូមឲ្យលោក មាស-សាម បោះពុម្ពផ្សាយរឿងនេះឲ្យចប់ ដើម្បីឲ្យប្រជាជនយើងនឹងនិស្សិតខ្មែរបានក្រេបជញ្ជក់អត្ថរសអក្សរសាស្ត្រយើង ។

ង) រឿងសុភាទន្សាយ — រឿងនេះកើតឡើងតបទៅរឿងកិងកក់ត្រូ ហើយមិនខុសពីរឿងកិងកក់ត្រូប៉ុន្មានឡើយ ។ រឿងសុភាទន្សាយជាគំរូកាត់ក្តីមួយដែរ ។ នៅ

ក្នុងរឿងព្រេងនេះគេយកសុភាទន្សាយជាចៅក្រមផុតលេខ ១ ឯចំណែកក្នុងគំនិតខ្មែរគេលើកមហាក្សត្រជាចៅក្រមជាន់ខ្ពស់ៗ រឿងសុភាទន្សាយខាងកាត់ក្តីមានច្រើន ដូចរឿងខ្លាទោល ផេកត្រូវពស់វែកចឹក ។ល។

ក្រៅពីរឿងកាត់ក្តីនេះ អ្នកនិពន្ធប្រជាជនខ្មែរយើងបុរាណបានលើករឿងផ្សេង ១ ទៀតនិយាយត្រង់អំពីគំនិតអាកប្បកិរិយាប៉ិនប្រសប់ ប៉ិនប្រសប់របស់អាសុភាទន្សាយចៅក្រមជាន់ខ្ពស់ ។

ក្នុងរឿង «គេ មាន់ អក ខ្លា នឹងទន្សាយប្រជុំគ្នាធ្វើផ្ទះ» គេឃើញទន្សាយពូកែច្រើនណាស់ ។ ដើម្បីឲ្យដឹងឃើញច្បាស់សុភាទន្សាយចៅក្រមផុតលេខ យើងសូមស្រង់រឿងនេះមកពិចារណាខ្លះ ។

គេ មាន់ អក ខ្លា នឹងទន្សាយប្រាំនាក់ បានស្របយោ-បល់គ្នាធ្វើផ្ទះនាំគ្នាទៅរកប្រូកស្បូវ ។ ដល់កាលស្បូវគេក៏ធ្វើដៃ (កេង)៖ គបាត់ឲ្យខ្លាចាំដៃ ។ គេ មាន់ អក ទន្សាយទៅប្រូក

ស្បៀង ៗ គេ, មាន់, អក បានប្រើឲ្យប្រគស្រូវគ្មានហ៊ានឈប់ ឯ ចំណែកកអាទៅក្រមទន្សាយខូច ធ្វើពុតជាឈឺ ហើយគេច ដើរលេងទៅលបមើលខ្លាវិញ ៗ កាទៅលបមើលឃើញខ្លា ចាប់កាន់រួចល្ងាចអាសុភាទន្សាយ បានត្រឡប់មកកន្លែងប្រគ ស្បៀងធ្វើជាគ្រឿងញីរបស់គេ, មាន់, អក ទាយប្រែល្ងាច គេ ខ្លាគេអ្វីបានស៊ីៗ កាស្គាល់ថាមានកាន់ស៊ី ហើយបើកាលណា កាទាយត្រូវ គេ មាន់ អក មិនត្រូវស៊ីទេ បើកាទាយខុសវិញ គឺកាមិនត្រូវស៊ីដែរ ៗ ល្ងាចទៅដល់ដៃ កាធ្វើជាស្លូវខ្លា ហើយឃើញបានកាន់ស៊ីមែន កាហ្វូងហែងមិនឲ្យគេ មាន់ អក ស៊ី តែគេ មាន់ អក ដេរបន្ទោសស៊ីទាល់តែបាន ៗ

ថ្ងៃបន្ទាប់មកវេនទី២ ទី៣ ទី៤, ត្រូវវេនគេ អក មាន់ ចាំដេម្តងម្នាក់ ១. ៗ ម្នាក់ៗបានកាប់ដើមឲ្យលើវេនខ្លួនគេម្ប៉ស៊ី គ្រប់គ្រាន់ ៗ ឯចំណែកអាសុភាទន្សាយវិញ ទៅប្រគស្បៀង នៅតែប្រើគំនិតបោកស៊ីកម្លាំងគេជានិច្ច កាគេចធ្វើជាឈឺពោះ

ដើរលបមើលអ្នកចាំដៃទៅវិញ ហើយបបួលគាយមួយជុំ មុនទៀត ។

ថ្ងៃទីប្រាំត្រូវវេនអាសុភាទន្សាយចាំដៃ ។ ដោយវាមិនដែលប្រកបការកេសុីនឹងខ្លួនវាម្ដងឡើយ អាសុភាទន្សាយតាលតឹងជាខ្លាំងនឹងរកមួយឲ្យខ្លា ភេ មាន់ អក ទៅច្រូតស្រូវសុីល្ងាច ។ ម៉្លោះហើយវាដែលគ្មានការពិសោធន៍ក្នុងការធ្វើពលកម្មទិចសោះក៏ធ្វើការមិនសម្រេចឡើយ ដំបូងវាត្រាប់ខ្លាទៅរកចាប់គ្នាទ់ តែគ្មានមានមាឌធំបានតែវាដួលផ្កាប់មុខប្រឡាក់ភក់ពក្ដកអាក្រក់មើល ។ បន្ទាប់មកវាត្រាប់ភេទៅមុជចាប់ត្រីបានអួសវាជ្រមុជទឹក វាភ័យខ្លាចក្សួយបានលែងត្រីចោលហើយឡើងមុខក្រញោន ញ័រខ្លួនកំព្រាន់ដូចស្វា មុខមាត់សូញប្រូញណាស់ញ័រជើងដៃ ។ តមកទៀតអាសុភាទន្សាយត្រាប់អក ។ វាឡើងចុងឈើលោតចាប់ត្រីត្រូវត្រីនាំជ្រមុជទឹកទៀត ទន្សាយភ័យស្ទើរឡើង ៗ ...ភ្លុកវាស្លុក

មើលមុខតាក្រក់ស្លាប់តាំងសម្បុរសស្គាំង ហាក់ដូចមុខខ្មោចព្រាយ ។ល។

ចុងបំផុតវាត្រាប់មាន់ ៗ វាយកថ្នាំងមកចំអិតផុះហើយ វាស្មារកន្ទះថ្នាំងទុកឲ្យ កេ មាន់ អក ខ្លា អ្នកធ្វើការនឿយហត់ស៊ី ឯចំណែកវាវិញវាធ្វើពុតជាឈឺដេកថ្ងូរ ៗ វាស៊ីមិនបានទេ វាទុកឲ្យកេ មាន់ អក ខ្លា ស៊ី ៗ ដល់សត្វតាំងប្អូនស៊ីឆ្អែតវាមិនពាល់ពុតទេ ៗ វាក្រោកស្រែកថាគេស៊ីតាចម៍វា ៗ សត្វតាំងប្អូនខឹងដេញតាទន្សាយ វាតែញាក់ទៅៗ ដល់ល្ងាចសត្វតាំងប្អូនត្រឡប់មកវិញ សោយខឹងនឹងតាសុតាទន្សាយ ៗ ក៏ត្រឡប់មកវិញបបួលគ្នាដឹកស្រូវយកទៅផ្ទះ ៗ

គេស្រុះគ្នាផ្ទុកស្រូវលើខ្នងខ្លា ៗ ទន្សាយវាជិះបរខ្លា ហើយដុតស្រូវនោះឆេះពេញលើខ្នងខ្លា ៗ រត់ត្រវីត្រវាត់ ៗ ទន្សាយលោតរត់ទៅទៀងដើមសង្ក្រ ៗ ខ្លាតាមទៅទាន់ ប៉ងនឹងចាប់ទន្សាយខាំស៊ីឲ្យក្ស័យ ៗ លើកនេះទន្សាយដោះតាមកលល្បិច ចុកពោះឈើលែងបានទៀតហើយ ព្រោះ

គេបានស្គាល់ពុតវាអស់ ៗ ដូច្នេះវាក៏អួតបញ្ឆោតប្រាប់ខ្លាថា ទេវតា ព្រះឥន្ទ ទេព្រក្ស បានប្រើវាមកបួតស្ទឹកសន្ស័រ ហើយបើខ្លាហ៊ានស៊ីវា ខ្លាឯងមុខជាត្រូវចុះនរកយ៉ាំងជ្រៅ ៗ ខ្លាខ្លាចនរកដែលសុភាទន្សាយការបង្កើត ក៏ស្បថស្បែមិនព្រមហ៊ានស៊ីទន្សាយ ហើយសូមបួតស្ទឹកសន្ស័រលេងជាមួយផង ៗ តមកទៀតអាសុភាទន្សាយទៅក្រុមផុតលេខ បាននាំទៅយោលតោងលើវល្លិ៍ ទៅអង្គុយលើឫស្សីស្រងៀតគ្នា ទៅអង្គុយនៅបៀតសំបុកឪម៉ាល់ ដោះសារប្រាប់ខ្លាកុំឲ្យចាំងចឹងខ្លួនថា ស៊ុខ្លៃទេវតាព្រះឥន្ទប្រើខ្ញុំឲ្យមកលេងភ្លេង ៗ កលល្បិចនេះបានធ្វើឲ្យខ្លាធោតល្ងង់ជឿថាទេវតា ព្រះឥន្ទ ទេព្រក្ស ត្រូវដាប់តោងដូល ត្រូវ[illegible]ខ្លាយកក្លុយត្រូវឪម៉ាល់ទិច ៗ ទីបំផុតទន្សាយត្រូវខ្លា[illegible] [illegible]ក៏ភ័យទៅធ្លាក់អណ្តូង តែវានេះកលល្បិចបានបញ្ឆោតបំភ័យថាមេឃលើលើ ៗ ខ្លាភ័យក៏តែបួលទៅក្នុងអណ្តូង ៗ បន្ទាប់មកខ្លាចឹងចឹងទន្សាយ ក៏បោះទន្សាយចេញ

មកក្រៅអណ្ដូង ហើយទន្សាយរួចពីអណ្ដូងក៏ស្រែកឲ្យអ្នកស្រុកសម្លាប់ខ្លាហោង ។

សុភាទន្សាយចៅក្រមផុតលេខ បានប្រើគ្រប់កលល្បិចបោកប្រាស់អ្នកមានកម្លាំងកាយដែលគ្មានវិជ្ជា ។ ចង់ស៊ីចេក «ទន្សាយធ្វើពុតជាស្លាប់ស្អុយ» ដើម្បីឲ្យយាយទូករចេកបែកញើសរើសរកដាក់ក្នុងកញ្ជើ ។ ជាប់អន្ទាក់ទន្សាយក៏យំណាស់ខ្លាចមនុស្សស៊ីក៏អង្វរគីង្គក់ឲ្យជួយដោះខ្លួន សន្យាថានឹងមើលស្រែឲ្យជា ។ រួចពីគ្រោះថ្នាក់កាលណាទន្សាយចំអកឲ្យគីង្គក់ថា ស្រែពីដីដូនជីតាមកគ្មាននរណាមើលជាទេ ។ល។

ក្នុងរឿង «គោ មាន់ អក ខ្លា ទន្សាយ» នេះ យើងបានសង្កេតឃើញថា តាសុភាទន្សាយ «ចៅក្រមផុតលេខ» គ្មានធ្វើការអ្វីទេ គិតតែដើរបោក ហើយគេ កូតយកទៅតាទេព្រ័ក្ស ព្រះឥន្ទមកបោកខ្លា ដែលជាអ្នកមានកម្លាំងធ្វើការច្រើនជាងគេ ។ សូមបងប្អូនអ្នកអានពិចារណារឿងនេះឲ្យមែនទែន ។

## អក្សរសាស្ត្រខ្មែរក្នុងសម័យអាណានិគមនិយមបារាំង ទល់ឆ្នាំ១៩៤៥

នៅសតវត្សទី១៨ នៅប្រទេសអឺរ៉ុបវិទ្យាសាស្ត្រនិងតិកនិក បានចំរើន ឧស្សាហកម្មត្រូវសារបានរណាយ ហើយទុកកន្លែងឲ្យឧស្សាហកម្មកើតច្រើន ៗ ដែលប្រើកម្មករគូលីរាប់ពាន់នាក់ ៗ ការបង្កើនផលបានលឿនលឿន ជាបុព្វហេតុមួយធំ ជម្រុញឲ្យប្រទេសអឺរ៉ុបនាយទុនដើររុកទន្ទ្រានរកប្រទេសចំណុះ ដើម្បីធ្វើជាផ្សារសម្រាប់លក់ទំនិញវា ហើយនិងទិញទំនិញវត្ថុធាតុដើមត្រឡប់ទៅវិញ។ ដូច្នេះហើយបានជាប្រទេសនាយទុនបារាំង អង់គ្លេស ហុល្លង់ដែល បានមកដណ្តើមគ្នាដះដាន

បណ្ដាប្រទេសនៅអាស៊ីមាន ឥណ្ឌៀ ឥណ្ឌូណេស៊ី ម៉ាឡាយូ ឥណ្ឌូចិន ហ្វីលីពីនជាដើម ។

នៅប្រទេសឥណ្ឌូចិនខ្មែរ លាវ វៀតណាម ត្រូវអាណានិគមនិយមបារាំងដាក់ជាចំណុះរបស់វា ។ វិធីដម្បូងគឺវាប្រើលោកសង្ឃកាតូលិកឲ្យមកប្រចុះប្រចែង ប្រដៅសាសនាយេស៊ូគ្រិស្ដ ។ បន្ទាប់មកវាក៏យកកាំភ្លើងនឹកប៉ាល់បន្ទុំស្រុកខ្មែរយើងឲ្យដាក់ខ្លួនជាចំណុះវា ។ តែការជិះជាន់របស់អាណានិគមនិយម បានជួបប្រទះការតស៊ូដ៏អង់អាចរបស់ប្រជាជនខ្មែរយើង ។ លោកអាចារ្យស្វា, ពោកំបោរ, ស៊ីវត្ថា, ហែម-ចៀវ, បានសរសេរប្រវត្តិសាស្ត្រតស៊ូទុកជាកេរ្តិ៍តំ-ណែលឲ្យយើងគ្រប់គ្នា ។ ព្យាករណ៍ទាំងនោះ ពួកអាណានិគមនិយមបារាំងបានកែងដាក់ជាអ្នក «ក្បត់ជាតិ» ទៅវិញ ។

ក្រោយដែលដាក់ប្រទេសយើងជាចំណុះអាណានិគមនិយមបារាំងបានប្រើគ្រប់កលល្បិច បំផ្លាញបំបាត់ប្រជាជាតិខ្មែរយើងពីផែនទីសាកលលោក ។

ខាងនយោបាយក៏ផ្អែកលើរបបសក្តិភូមិ ហើយបាន បង្កើតភ្នាក់ងារនាម៉ឺនឲ្យបន្តផែកទៅច្របាច់ប្រជាជនយើង ។ ខាងសេដ្ឋកិច្ច ក៏បង្កើតពន្ធមួយរយចំពូក ជាន់កប្រជាជនយើង ហើយក៏ចាប់ដីខ្វាញ់ ៗ ធ្វើជាចំការកៅស៊ូទឹងបញ្ជូនវត្ថុដើមនិង ទ្រព្យសម្បត្តិទៅប្រទេសគេ ៗ សារូបទៅជាង៨០ឆ្នាំ ក្រោម នឹមដែកអាណានិគមនិយម, ប្រជាជនយើងត្រូវគេខ្ទប់មាត់ បិទភ្នែក ចុកត្រចៀក គ្មានស្គាល់សេរីភាពសិទ្ធិបន្តិចឡើយ ៗ

ពោសទុក្រិដ្ឋរបស់អាណានិគមនិយម មិនមែនអស់ត្រឹម ដូចក៏រៀបខាងលើនេះទេ ៗ ខាងវប្បធម៌ ក៏ប្រើគ្រប់វិធី បំបាត់អក្សរសាស្ត្រយើង ៗ ក៏មានគ្រោងការសិក្សាបង្វែរកូន ខ្មែរឲ្យបោះបង់វប្បធម៌របស់ជាតិខ្លួន ៗ កលល្បិចក៏មានច្រើនៈ

១-បង្កើតសាលាបារាំង-ដើម្បីបង្ហាត់បង្រៀនកូន ខ្មែរឲ្យធ្វើជើងឈ្នួល បន្តដៃពួកអាណានិគមបារាំង

ក៏សង់គុកច្រើនជាងសាលារៀន ៗ ប្រជាជនជាងបួន លាននាក់ មានវិទ្យាល័យតែមួយ ៗ ឯចំណែកកន្លែងគ្រែក

ត្រអាលកំសាន្តសម្រាកសម្រាប់ពួកវាមិនខ្វះទេ ដូចផ្ទះទៅកែប បូកគោ ចុងកាឡូ ។ល។ ចំពោះផ្ទះទាំងនោះប្រជាជនខ្មែរមានការៈគ្រាន់តែទៅសង់ ទៅជួសជុល ទៅបោសលានជាការស្រេច ។

គោលបំណងសាលាបារាំង គឺខំភកំងកូនខ្មែរ កុំឲ្យមានវិជ្ជាលើសពីឆ្លើយ «វី! ណុង! (បាទ! ទេ!)»។ វាបង្ខំកូនខ្មែរឲ្យរៀនភាសាបារាំង ។ បណ្តុះយើងឲ្យមានសតិអារម្មណ៍យល់ថា ភាសាបារាំងថ្កើង ហើយទាញយើងគ្រប់គ្នាឲ្យខ្ពើមមាក់ងាយអក្សរជាតិយើង ។

ក្នុងកម្លុងជាង ៨០ ឆ្នាំ កូនខ្មែរដែលបានរៀនបារាំងឈប់ស្គាល់អារ្យធម៌ខ្មែរ, វប្បធម៌ខ្មែរ ហើយថែមទាំងអណ្តែតអណ្តូងទៅតាមឃោសនាវា ជឿថាខ្មែរគ្មានវប្បធម៌គ្មានអក្សរសាស្ត្រផង ។ អារ្យធម៌ដែលអាណានិគមនិយមយកមកបង្រៀនយើងគឺអារ្យធម៌អាណានិគមនិយម មិនមែនអារ្យធម៌ប្រជាជនបារាំងទេ ។

**នៅគ្រប់ផ្លូវការ** **វា**ទាត់ចោលអក្សរខ្មែរយើង ហើយ**វាយក** **ភាសាបារាំងមកប្រើជំនួស** ។ ខ្មែរចេះខ្មែរ គ្មានតម្លៃ **ខ្មែរណាចេះបារាំងមួយ**ម៉ាត់ពីរម៉ាត់ អាចបានធ្វើកូន **«លោកធំ»** ។ គំនិតក្រខ្វក់លាមករបស់វា មានច្រើនទៀត **យើងមិន**អាចរៀបរាប់ទាំងអស់បានឡើយ ។

## ២– ក្តាប់បណ្ឌិតអក្សរសាស្ត្រខ្មែរ ដើម្បីលាក់អំពើ

**លាមកវា** ដែលបដិសេធអក្សរសាស្ត្រខ្មែរពីគ្រប់ផ្លូវការ គ្រប់ **ក្រសួង** វាធ្វើបញ្ឆោតបោកកូនខ្មែរថាវា បានថែរក្សាទម្លាប់ខ្មែរ ដោយបង្កើតពុទ្ធសាសនបណ្ឌិត ហើយប្រមូលអ្នកប្រាជ្ញ ឲ្យមកធ្វើការបំរើវា ។ ដោយវិធីនេះ កាណានិគមនិយម បារាំង បានចូលទៅក្តាប់លោកសង្ឃឲ្យដើរស្របតាមនយោបាយវា ។ ការចាត់តាំងរើសមេគណៈមានវាជាគណៈ ជាដើម សុទ្ធតែត្រូវតែគ្រោះទទួលយល់ព្រមពី «លោកធំ» ទាំងអស់ ។ អ្នកស្រីការលើលៃស ជាភ្នែកច្រមុះរបស់វា ដើម្បីក្តាប់បញ្ញាបណ្ឌិតខ្មែរនៅក្រោមបង្គាប់គាត់ ឲ្យធ្វើការតម្រូវ

នយោបាយអាណានិគមនិយម ។ ដូច្នេះ អាណានិគមនិយម អាចមើលស្ទង់គំនិតអ្នកប្រាជ្ញខ្មែរខ្លះ តើមានគំនិតជួយនឹងរបបការទេ ក៏នឹងស្រួលចាប់ចង ។ ម្យ៉ាងទៀត ដោយវិធីនេះ ក៏បានឃាត់កូនខ្មែរកុំឲ្យទៅរៀនប្រទេសក្រៅ ។ល។

៣- នៅក្នុងរបបអាណានិគមនិយមអក្សរសាស្ត្រខ្មែរសាបសូន្យ គ្រោងការអាណានិគមនិយមបាក់ដៃគឺ បំ-បាត់ប្រជាជាតិខ្មែរ ។ ធម្មតាតែប្រជាជាតិបាត់អក្សរសាស្ត្រមុខជាសាបសូន្យ ។ ដូច្នេះហើយបានជានៅក្នុងរវាងជាង ៨០ឆ្នាំ អ្នកប្រាជ្ញខ្មែរពិតប្រាកដមិនបានគង់វង្សមានច្រើន ហើយក៏មិនបានទុកស្នាដៃដូចរយៈមុនឡើយ ។ ក្នុងនឹមចក្រពត្រអ្នកប្រាជ្ញប្រជាជនកើតមិនបានទេ ព្រោះគ្រាន់តែរៀបជុះពន្លក ត្រូវពួកចក្រពត្រអាណានិគមនិយមក្តិចះចោលភ្លាមហើយបំ-ផ្លាញពាក្យ ថាក្បត់ ថាចោរ ក៏សឹងមាន ។ អាចារ្យហែម-ចៀវ ជាភស្តុតាងស្រាប់ ។

បើយើងនិយាយដូច្នេះប្រហែលជាពួកអាណានិគមនិយម

ខ្លះ បានឆ្លើយតបមកវិញថា យើងនិយាយឲ្យរួចតែពីមាត់ ដោយឃើញកាណានិគមនិយមបាក់ផ្លូលដេកក្រោម ហើយ គេមុខតែចង្អុលប្រាប់យើងថា កាណានិគមនិយមបានបើក ផ្សាយៈសៀវភៅកម្ពុជសុរិយា ហើយបានទាំងបើកច្បាប់ឲ្យ ផ្សាយអក្សរសាស្ត្រចំណាន ៗ «ដូចគតិលោក» របស់លោក សុគន្ធ ប្រីជាន់ទួ ជាដើម ៗ លោកតាក្រុម ង៉ុយ ដែលជាកវី ប្រជាជន ក៏ត្រូវបានអនុញ្ញាតផ្សាយច្បាប់ប្រុសគាត់ដែរ ។ យើងគ្មានជំទាស់នឹងយោបល់ខាងលើនេះទេ ៗ យើងគ្រាន់តែ ជំពបថា ចំនួនសៀវភៅផ្សាយមានស្តួចស្តើងណាស់ ហើយ សៀវភៅទាំងនោះ ក៏គ្រាន់តែជានាំផ្លូវដឹកនាំប្រជាជនឲ្យសុខ ចិត្តនៅក្រោមរបបចក្រពត្រៃតប៉ុណ្ណោះ ៗ កម្ពុជសុរិយាច្រើន បានចុះសេចក្តីប្រែអត្ថបទរបស់អ្នកនិពន្ធបាកំងខ្លះ នឹងព្រឹត្តិ ការណ៍ទទួលលោកធំបាកំងនោះជាការចម់ ៗ ក្រៅពីនេះ មានប្រែធម៌បាលីខ្លះ ដែលសុទ្ធតែបាកំងពិនិត្យមើល

មុន ៗ តទៅនេះយើងសូមពិនិត្យមើលសៀវភៅ «គតិ-
លោក »

«គតិលោក» — ក្នុងរបបអាណានិគមនិយម អ្នកនិពន្ធគ្មានសេរីភាពសរសេរបោះពុម្ពផ្សាយយោបល់ខ្លួនទេ ៗ ព្រោះសៀវភៅធម៌ក្តីត្រូវរាជការបារាំងពិនិត្យសិន លុះរាជការយល់ព្រមទើបបោះពុម្ពផ្សាយបាន ៗ ដូច្នេះហើយ សៀវភៅក្បួនខាំង ប៉ុន្មានត្រូវសរសេរដូចម្តេចគោរពសរសើរ ដល់របបអាណានិគមនិយម ហើយបើហានទាស់ទៀតវិញ ត្រូវគេធ្វើទោសជៀសមិនផុតឡើយ ៗ ក្នុងគតិលោកខ្សែពិរ លោកកាឌុកបានលប គន់រឿង «កូនចៀមនិងចចក» បញ្ចូលគំហើញទាស់ទៀនដល់របបផ្តាច់ការបុរាណសម័យនោះជាសេចក្តីថា:

« មួយទៀត បើនរណា ពួកណាប្រទូស្ត គឺក្បត់ផែនដី ប្រទូស្តនឹងទ្រង់ស្តេចជាព្រះមហាក្សត្រិយ៍ទី ច្បាប់ត្រូវប្រហារជីវិតទាំងត្រកូល ឯពួកញាតិពូជនោះ ត្រូវទម្លាក់ដាក់ជាពល ជាអ្នកងារ មានឲ្យត្រូវបោចសក់សេះសក់ដីរ...

ត្រាអស់កប្បអស់កល្បទៅ ៗ សត្វដែលកើតក្នុងវង្សនោះចុះ ឈ្មោះជាអ្នកងារជាលេខមួយទាំងអស់ ទោះប៉ុន្មាន ៗ គ ក៏ពុំ រួចផុតពីព្រៃងារទឹងគេឡើយ ៗ សត្វណាដែលកើតក្នុងពូជនោះ ទោះជាចេះវិជ្ជាការអ្វី ១ ឬមានប្រាជ្ញាយ៉ាងណាក្តី ក៏តាំងខ្លួន ពុំបានហៅថាសត្វឥតកំពុកក្នុងលោកនោះឯង ៗ ច្បាប់ដែល ហាមកនេះ ជាប់ជាទម្ងន់ទៅខាងអ្នកទាបប្រាកដ មួយទៀត ច្បាប់នេះ បើមាននៅក្នុងប្រទេសណាហើយ អ្នកប្រាជ្ញណា នឹងគិតគេចឲ្យរួចចេញទៅពុំបាន បើចង់រួចចេញនោះបានតែ រត់ចោលស្រុកភៀសខ្លួនទៅប្រទេសដទៃៗទៀត នោះទើប បាន ដូចនិទានលោកតាសុខពង្ស» ៗ

គតិលោកនឹងច្បាប់តាន់ហ៊ុយក៏មិនអាចហ៊ានបញ្ចេញគោល បំណងទិទៀនលោកធំណា ដោយពេញមុខឡើយ ព្រោះ ច្បាប់ទាំងនោះត្រូវឲ្យបារាំងត្រួតត្រាពិនិត្យ ព្រោះប្រជាជន គ្មានសេរីភាពនិងសិទ្ធិសរសេរនិយាយបោះពុម្ពផ្សាយ ៗ

ហេតុនេះយើងអាចយល់ថា «គតិលោក» ជាច្បា

ស្របពេញទីទៅតាមពាក្យទូន្មាន អាណានិគមនិយមនិងសក្តិភូមិ ។ ចំពោះសៀវភៅគាត់នេះ លោកតាឥន្ទ បានផ្តើមសេចក្តីថា

«តម្រាគតិលោក ខ្ញុំបាទឧកញ៉ា សុត្តន្តប្រីជាឥន្ទអ្នកតែងឡើង ដើម្បីកុលបុត្រអ្នករៀនគតិបូរាណ ជាបែបយ៉ាង គ្រាន់តាងសេចក្តីប្រៀបនាំមកប្រាព្ធគតិលោកថ្មី ដែលកើតមានឡើងទើបតាំងជាបុច្ឆា (សួរ) និងពាក្យវិសជ្ជនា (ឆ្លើយ) ក្នុងតម្រានេះ ជាទីសណ្តាប់ដោយងាយ» ។

ក្នុងសេចក្តីផ្តើមនេះ យើងអាចសង្កេតឃើញពាក្យ «គតិបូរាណ» និង «គតិលោកថ្មី» ដែលមានន័យដូចខាងក្រោមនេះ ។

ពាក្យ «គតិលោកបូរាណ» មានន័យជាច្បាប់សក្តិភូមិ គឺមុនបារាំងអាណានិគមនិយមបារាំងចូលមកមាន «ច្បាប់ក្រមត្រៃនេតិ ច្បាប់ស្រី» ។

ពាក្យ «គតិលោកថ្មី» មានន័យជាច្បាប់លោកសម័យ

អាណានិគមនិយម (ចក្រពត្រ) លាយឡំនឹងសក្តិភូមិ ។

ដូចន័យខាងលើនេះ យើងឃើញថាសៀវភៅ «គតិលោក» ជាដំបូន្មានរបស់រាជការអាណានិគមនិយម ដែលផ្អែកទៅលើសក្តិភូមិ ។ បើដូច្នេះ យើងអាចថា «គតិលោក» មានផ្នែកខ្លះហួសសម័យប្រទេសយើងសព្វថ្ងៃ ឯករាជ្យប្រជាធិបតេយ្យ សព្វថ្ងៃ ។ ហេតុនេះ យើងត្រូវបដិសេធចោលគតិណា ដែលហួសម័យត្រូវ ។

តែបើយើងនិយាយខាងអក្សរសាស្ត្រវិញ យើងឃើញថាលោកគាត់ឧ្ម ជាអ្នកនិពន្ធមួយចំណានក្នុងជំនាន់គាត់ ។ គតិលោករបស់គាត់ បានបញ្ចាំងឲ្យយើងឃើញការរស់នៅសង្គមជាច្រើន ។ លោកគាត់ឧ្មបានជ្រើសរើសលើករឿងជាតំណែងឲ្យយើងឃើញដូចរឿងឃុនកំភ, ចៅសន, រឿងពាលហួសប្រមាណ ។ល។ ដែលគ្មានសៀវភៅណាមួយក្រៅពីនេះទុកឲ្យយើងដឹងឡើយ ។

ម្យ៉ាងទៀត លោកគាស់ត្ពនប្រើជាឥន្ទ ដែលជាអាចារ្យ

ព្រះពុទ្ធសាសនាមួយយ៉ាងឯក បានប្រដៅយើងកុំឲ្យជឿអ្នកតា យាយទេពធ្វើសក្ការៈបូជាទឹកបឹងផ្តេសផ្តាស ។ ត្រង់ចំណុចនេះ លោកតាឥន្ទ បានអធិប្បាយយ៉ាងក្បោះក្បាយនៅក្នុងគតិលោកខ្សែបី ត្រង់រឿងធ្វើសក្ការ; បូជាទឹកបឹង, ដើមដង្កោ, គោស្នាវខ្មៅ, យាយទេព, រឿងភ្នំក្រោមនៅខេត្តសៀមរាប នឹងភ្នំត្រនិលនៅក្នុងស្រុកជើងព្រៃ ។ល។

**ច្បាប់ក្រមង៉ុយ**– លោកតាង៉ុយបានសរសេររឿងប្រដៅប្រជាជនបីប្អូនច្បាប់ដែរ ។ គាត់ជាកវីប្រជាជន ។ គាត់បានជួយឈឺឆ្អាល ដោយឃើញរាជការបារាំងដាក់ពន្ធរស់ផងជាច្រើន ហើយដាស់តឿនប្រជាជនឲ្យខំធ្វើការ ។ គាត់ប្រដៅលោកសង្ឃកុំឲ្យទាស់គ្នាពីធម៌ថ្មីចាស់ ហើយនឹងសូមកុំឲ្យលោកសង្ឃសុំលុយចិនចាយ ។ តែដូចលោកតាឥន្ទ លោកតាង៉ុយ ក៏ស្របទៅតាមរបបសក្តិភូមិគាណានិគមនិយមទាំងអស់ ។

## អក្សរសាស្ត្រខ្មែរក្រោយសង្គ្រាមលោកលើកទីពីរ

នៅឆ្នាំ១៩៤៥ ក្រោយដែលកងទ័ពសហភាពសូវៀត បានរំដោះមនុស្សជាតិពីក្រញាំហ្វាស៊ីស្ត អាល្លឺម៉ង់និងហ្វាស៊ីស្ត ជប៉ុន, អ៊ីតាលី, ប្រជាជននៅស្រុកចំណុះចាំងប៉ុន្មាន បាន ក្រោកឡើង តស៊ូដើម្បីយកឯករាជ្យ ប្រជាធិបតេយ្យ ។ ស្ថានការណ៍ សាកលលោកនឹងការតស៊ូប្រជាជនខ្មែរគ្រប់ជាន់ ថ្នាក់ បានបង្ខំចក្រពត្រូវបារាំងលាក្រញាំបន្តិច ។ អាណានិគម និយមបារាំង បានត្រូវបង្ខំបើកអំណាចឲ្យយើងមានសេរីភាព បន្តិចបន្តួច តែអំពើយង់ឃ្នងឃោរឃៅក៏មាននៅដដែល ។ ប្រជាជនខ្មែរបានបង្ហូរឈាមតស៊ូរៀងរហូតមក លុះដល់ ជ័យជំនះហ្សឺណែវនៅថ្ងៃ២១ កក្កដា ១៩៥៤ ដែលសម្រេច

ប្រទេសយើងបានសន្តិភាព ឯករាជ ប្រជាធិបតេយ្យ ។

ក្នុងរយៈនេះ តើអក្សរសាស្ត្រខ្មែរយើង បានប្រែចំរើន ដូចម្តេចខ្លះ ? យើងអាចសង្កេតឃើញពិតមែនតែត្រូវអាណានិគមនិយមបុកម្នាត់ ចាប់ចង់អ្នកនិពន្ធរឿងផ្សេងៗជាច្រើន បានកើនចំនួនជាលំដាប់ ។ អ្នកនិពន្ធខ្មែរបានអត់ងងុយសរសេរប្រលោមលោក មានខ្លះបកប្រែចេញពីសៀវភៅភាសាជាតិដទៃ ។ ស្ទើរពេលត្រីមាស មានសៀវភៅថ្មីៗ ជាច្រើនក្បាលចេញផ្សាយលក់គ្រប់បណ្ណាគារក្រុង ខេត្រ ដែលខំត្រដរកើតឡើង ។

ប្រៀបនឹងគ្រាល្បងសម័យមុន យើងឃើញប្រលោមលោកមានដំហានចំរើនគ្រាន់បើ ព្រោះអ្នកនិពន្ធប្រលោមលោកយើង បានជ្រើសរើសតួឯកនៅលើដីមិនឲ្យអណ្ដែតអណ្ដូងឡើងទៅរកសក្តិពូជពង្សបានលើទេ ។ យើងឃើញរឿងប្រលោមលោកទាំងនោះ ច្រើននិពន្ធពី «ប្រុសប្ដីស្រី» កំសត់ [illegible] សោកសៅទៅឋបនឹងអ្នកមានធនធាន ឬ មានយស

សក្តិ មានចិត្តសទ្ធាជ្រះថ្លាជួយចិញ្ចឹម ។ ជួនកាលអ្នកមានជ្រះថ្លាបានយក «ប្រុសបុស្រី» កំសត់ធ្វើជាកូនប្រសា, កូនចិញ្ចឹម ឬប្រពន្ធទៅក៏មាន ។ បន្ទាប់មកអ្នកកំសត់នោះ ក៏បានទីសុខស្រួលនៅក្នុងតំណែងថ្មី ។ រឿងពួកនេះមាន «សុជាត» «កូឡាបប៉ៃលិន» «ទ្រូងអាធាឋា» ។ល។ រឿងនេះបានឲ្យយើងយល់ថា អ្នកនិពន្ធបំពេអ្នកអានឲ្យយល់ឃើញថា មានតែពួកអ្នកមានធនធាននាយទុនទេ ដែលអាចជួយធុរៈមនុស្សកំសត់ ម្ល៉ោះហើយ គេត្រូវចេះបំរើផ្គាប់ផ្គុនចៅហ្វាយនាយអ្នកមាន ក្រែងមានសំណាងបានធ្វើកូនប្រសា ប្រពន្ធកាន់ដំណែងជួស ហើយដល់មានទ្រព្យកាលណាគេក៏ដេកស៊ីជិះឡានដើរលេងមានខ្ញុំបំរើ ។ល។

យើងឃើញមានរឿងម្យ៉ាងទៀត ច្រើនដកទៅរករបៀបបុរាណនិយម ។ គេច្រើនលើករឿងស្ដេចក្នុងសម័យបុរាណរួចចម្លងក្បាច់លោកកាប់សម្លាប់ចម្បាំងនៅក្នុងភាពយន្តដែលពួកអាណានិគមនិយមចក្រពត្រនិយមបារាំង អាមេរិកាំង

បានបញ្ចូលមកបញ្ចាំង ។ សៀវភៅរបៀបនេះមាន «ព្រះមកុដពេជ្រ ព្រះចន្ទរាជា» ។ល។ ។

សៀវភៅ «សង្គ្រាមជានិច្ច» មានដំណាលខ្ពស់ជាងពួកប្រលោមលោកឯទៀតក្នុងផ្លូវសង្គម ។ អ្នកនិពន្ធបានផ្ដិតរឿងពិតជាក់ស្ដែងច្រើនកន្លែង ក្នុងជីវភាពប្រជាជនពួកយើង ។ អ្នកនិពន្ធជាអ្នកប៉ិនចំណានមួយ ខាងប្រើប្រយោគវគ្គ ពាក្យខ្មែរសមល្អ ។ តែអ្នកនិពន្ធនៅយកការយល់សប្ដិជាត្រីមុខ ហើយផ្អែកលើកំណាប់ក្នុងរូងឈើ មិនបានចុះស្រាវជ្រាវទៅមើលស្ថានការណ៍ប្រជាជនពិតប្រាកដ ។

សរុបទៅ សៀវភៅប្រលោមលោកយើងទាំងអស់គ្មានគោលអ្វី ដឹកនាំប្រជាជនឲ្យភ្ញាក់រលឹកទៅរកផ្លូវចំរើនភ្លឺស្វាងទេ ។ សៀវភៅខ្លះ បានបែរត្រឡប់ថយក្រោយវិញ ទៅរកសរសើររបបសក្ដិភូមិនាយទុនទៅវិញ ។ អ្នកនិពន្ធប្រលោមលោកយើង មិនទាន់ដុះលាងស្វាបបាកាឲ្យអស់កំអែលអាណានិគមនិយមចក្រពត្រិៈ ឡើយ ។

ក្រៅពីសៀវភៅប្រលោមលោក យើងមានសៀវភៅមួយផ្នែកទៀត ដែលយើងសន្មតហៅថា «សៀវភៅប្រជាធិបតេយ្យ» ។ រដ្ឋធម្មនុញ្ញនិងអត្ថាធិប្បាយរដ្ឋធម្មនុញ្ញ ជាសៀវភៅច្បាប់ ដែលកើតឡើងក្នុងរង្វង់ក្រោមការត្រួតត្រាអាណានិគមនិយម ។ សៀវភៅនេះ បានចែងទុកឲ្យយើងមានសេរីភាពសិទ្ធិក្នុងការនិយាយក្នុងការសរសេរ ។ តែសេរីភាពសិទ្ធិទាំងនោះ បានត្រូវពួកចក្រពត្តិនិយមរំលាយចោលទៅវិញ ដោយប្រើច្បាប់អយុត្តិធម៌ដាច់ខាតមកវិញ ។

ចំពោះសៀវភៅប្រជាធិបតេយ្យពិត ៗ នេះ យើងអាចរាប់សៀវភៅសិក្សាទាំងប៉ុន្មាន ដែលកើតឡើងក្នុងកម្ពុជ ៨-៩ ឆ្នាំ៖ ទស្សិកាយពួកទមិឡបោកិង ។ បងប្អូនយើងដែលរួមជាកម្លាំងខែទស្សិកាយអាណានិគមនិយមបារាំង ចាប់តាំងពីក្រោយសង្គ្រាមលោកលើកទីពីរលេតទៅ បានបង្កើនខ្នាតរៀបរៀងប្រវត្តិសាស្ត្រជាច្រើន ។ យើងសូមស្រង់ឯកសារខ្លះ ៗ

សៀវភៅ «គស្សិយូរនៃផ្ទឹងពិបាក [illegible]

ប្រាកដមានជ័យជំនះ» បានវែកញែកបង្ហាញផ្លូវយើងអំពីធម៌សាមគ្គីរវាងប្រជាជនខ្មែរ ព្រមទាំងវែកញែកអំពីហេតុគេទដែលបណ្តាលឲ្យចក្រពត្តិនិយមបារាំងត្រូវតែបរាជ័យ ព្រោះចំបាំងដែលរាប់កើតឡើងជាអំពើអយុត្តិធម៌ណាមក ។

សៀវភៅ «ការរំជួលបដិវត្តន៍នៅប្រទេសខ្មែរ» បានបង្ហាញឲ្យយល់ជាក់ថា តាំងពីបារាំងមកប្លន់ប្រទេសយើង ប្រជាជនយើងបានក្រោកតស៊ូជាលំដាប់ ដូចមានរឿងអាចារ្យស្វា, ពោកំបោរ, ស៊ីវត្ថា, អាចារ្យហែម-ចៀវ។ល។ ហើយនឹងអំពើកលល្បិចហ្វាស៊ីស្តជប៉ុនចង់បង្កើតក្រុម «ផ្កាយខៀវ» ហ្វាស៊ីស្តបញ្ចូលប្រទេសយើងឲ្យទៅក្នុងសង្គ្រាមរាវ ។

សៀវភៅ «អាកប្បកិរិយារៀនសូត្រ» បានពន្យល់យើងឲ្យឃើញថា មានរបៀបរៀនសូត្របីយ៉ាង

១) របៀបចក្រពត្តិនិយមគិតតែរៀនចេះ ដើម្បីជិះជាន់ប្រជាជន ។

២) របៀបអនុត្តនគឺឃុំឃ្លាំង រៀនសម្រាប់ធ្វើនាម៉ឺន

យកបុណ្យសក្តិយសអ្នកគ្រងក្លាងបំរើបក្រពត្រនិយម ។

៣) របៀបរណ្ណៈអធនគឺរៀនដើម្បីដោះទុក្ខអកុសលកម្ម មានកម្មករកសិករឲ្យចាកផុតអំពីអំពើអយុត្តិធម៌ ។ របៀបរៀនសូត្រ ដើម្បីដោះទុក្ខប្រជាជនទនេះ បានអាចនាំយើងទៅរកផ្លូវយុត្តិធម៌ពិតប្រាកដ ។

សៀវភៅ «ព្យាយាម, សំរេច, សុចរិត, សម្មាទិដ្ឋិ» ជាសៀវភៅមួយ បានដឹកនាំយើងឲ្យចេះដឹកនាំខ្លួនក្នុងការរៀនសូត្រ ធ្វើការប្រតិបត្តិក្នុងការថែរក្សាសំរេចសំរៀកបំពាក់ក្រដាស ។ល។

ក្រៅពីសៀវភៅ ដែលមានឈ្មោះខាងក្រោមនេះ យើងអាចឃើញមានសៀវភៅច្រើនទៀត និយាយពីប្រវត្តិប្រជាជនខ្មែរគេសិក្សាជាង ៨-៩ ឆ្នាំ ។ យើងអាចឃើញមាន «ប្រវត្តិរូបអាចារ្យ ហែមៈចៀវ ។ល។ សៀវភៅទុក្ខសកាសិក» ប្រកាសឯករាជ្យអំពាវនាវប្រជាជនខ្មែរគ្រប់ជាន់ថ្នាក់ឲ្យក្រោកឡើងវាយអាណានិគមនិយមបារាំង និងដៃជើងវា ។

សៀវភៅ «មិត្តម្នាក់» បានរៃកញែកអំពីដំណើរប្រតិភូខ្មែរ ទៅកាន់ប្រជាជនខ្មែរនៅស្រុកយៀកណាម ហើយចង្អុលថា មានតែប្រជាជនទេ ដែលជាមេកម្លាំងពិត ៗ នៃប្រជាជាតិ

x

x x

# អក្សរសាស្ត្រខ្មែរ ក្នុងសម័យសន្តិភាពឯករាជ្យ ប្រជាធិបតេយ្យ

ក្រោយដែលបានពិនិត្យមើលអក្សរសាស្ត្រខ្មែរគ្រួសាៗ តាំងពីសង្គមសក្តិភូមិ -សង្គមអាណានិគមនិយម (ចក្រពត្រ) យើងត្រូវសួរ តើអក្សរសាស្ត្រខ្មែរយើងត្រូវមានចរិតសំខាន់ៗអ្វីខ្លះក្នុងប្រទេសឯករាជ្យសន្តិភាព, ប្រជាធិបតេយ្យ ?

ដំបូងយើងត្រូវបដិសេធគំនិតយល់ខុសថា៖ «សិល្បៈសម្រាប់តែសិល្បៈ» ឬ «កំណាព្យសម្រាប់កំណាព្យ» ឲ្យជ្រះស្រឡះ ព្រោះដូចយើងបានរុករកមើលអក្សរសាស្ត្រខ្មែរមក ហើយ សិល្បៈឬកំណាព្យសុទ្ធតែកើតឡើងពីមនុស្ស ហើយសម្រាប់ក្រុមមនុស្សណាមួយជាដាច់ខាតៗច្បាប់ក្រម ច្បាប់

ស្រីកើតឡើងសម្រាប់សង្គមសក្តិភូមិ ។ «គតិលោក» ក៏បានកើតឡើងក្នុងសម័យអាណានិគមនិយមហើយក៏ស្របទៅតាមរបបនោះឯង ។

ប្រទេសខ្មែរយើងសន្តិភាពឯករាជប្រជាធិបតេយ្យ ត្រូវតែមានអក្សរសាស្ត្រសម្រាប់សម័យប្រជាធិបតេយ្យនេះដែរ ។ មុននឹងនិយាយ តើអក្សរសាស្ត្រយើងត្រូវមានចរិតប៉ុន្មាន យើងសូមលើកពាក្យអ្នកប្រាជ្ញខ្លះមកជូនពិចារណា ។ អ្នកប្រាជ្ញចំណានម្នាក់បាននិយាយថា: «អ្នកទស្សនវិជ្ជា មិនគ្រាន់តែចម្លងហេតុការណ៍ដែលមាននៅក្នុងសង្គមប៉ុណ្ណោះទេ គឺអ្នកនិពន្ធត្រូវកែមធ្យោបាយ ដឹកនាំសង្គមឲ្យបានដើរទៅរកផ្លូវចំរើនយុត្តិធម៌» ។

ដូចសេចក្តីខាងលើនេះ អ្នកនិពន្ធត្រូវ[illegible] បង្ហាញផ្លូវដឿនលឿនចំរើ[illegible] អ្នកនិពន្ធត្រូវលើកតម្កើងគុណសម្បត្តិប្រសើរ ៗ នៃប្រជាជនទៅវិញមុខ មិនត្រូវមាននាទីបម្រើផ្តិតត្រង់សកម្មភាព ពួករឈ្មួញ

នៃសង្គមទ្រុឌទ្រោមទេ ។ ដើម្បីនឹងឲ្យស្គាល់ការតស៊ូយុត្តិធម៌ប្រជាជន អ្នកនិពន្ធត្រូវដាក់ខ្លួនជាប្រជាជន មិនត្រូវគ្រាន់តែចង្អើតៈឈោងមើលពីលើតែប៉ុណ្ណោះឡើយ ។ អ្នកនិពន្ធត្រូវសរសេររឿងមានលក្ខណៈប្រជាជាតិ ប្រជាជននិងវិទ្យាសាស្ត្រ ។

«ប្រជាជាតិ» បានសេចក្តីថា យើងត្រូវលើករឿងដែលមានចរិតប្រជាជាតិខ្មែរពិតៗ ។ ធម្មតាជាជាតិនានា មិនមានចរិតអាកប្បកិរិយានិងទេសភាព ដូចគ្នាទាំងអស់ទេ ។ អក្សរសាស្ត្រយើង ត្រូវដើរតាមលំនាំជានអក្សរសាស្ត្រជាន់មុនៗ ដៀនលៀនមានរឿងច្រើនជាដើម ។

«ប្រជាជន» បានសេចក្តីថា យើងលើកប្រជាជនជាធំៗ អ្នកតំរូវឯករបស់រឿងយើងទាំងប៉ុន្មាន គឺប្រជាជនកម្មករកសិករ អ្នកធ្វើការ ។ យើងមិនត្រូវដើរតាមជានរឿងសាស្ត្រល្បែងប្រឡោមលោកសម័យមុនជិត ១ នេះឡើយ ។ យើងត្រូវបន្តអក្សរសាស្ត្រប្រជាជនយើងមានអាឡោវ ចេញ

ផង សុភាទន្សាយ ។ល។ តែយើងត្រូវផ្ដាផ្លូវយុត្តិធម៌ ។ ប្រជាជនដើរទៅបានសុខសម្បូណ៌ ។ គុណវិបត្តិនៃរឿងព្រេង ប្រជាជនយើងសម័យសក្ដិភូមិ គឺចេះតែត្អូញត្អែរទឹង តែមិនចេះបង្ហាញផ្លូវយុត្តិធម៌ ព្រោះសម័យនោះការចេះដឹងយល់ឃើញនៅស្ដួចស្ដើងណាស់ ។

ម្យ៉ាងទៀតប្រយោគឃ្លា របៀបសរសេរ យើងត្រូវសរសេរឲ្យប្រជាជនងាយយល់ ។ យើងត្រូវបញ្ចាំងក្នុងរឿងការតស៊ូប្រជាជនទល់នឹងធម្មជាតិ ការតស៊ូស្វិតស្វាញប្រជាជនដើម្បីសិទ្ធិសេរីភាព សន្តិភាពប្រជាធិបតេយ្យ ។

«វិទ្យាសាស្ត្រ» បានន័យថា អក្សរសាស្ត្រយើង ត្រូវផ្អែកទៅលើការជាក់ស្ដែង យើងជម្រុះចោលនូវជំនឿគ្មានសមហេតុសមផល ។ យើងត្រូវផ្អែកលើវិទ្យាសាស្ត្រ ព្រោះមានតែវិទ្យាសាស្ត្រទេ ដែលអាចសម្រួលកម្លាំងប្រជាជនយើងក្នុងការបង្កើតផលិតផល ហើយនឹងអាចឲ្យយើងចាកផុតពីជំនឿគ្មានសមហេតុសមផល ។

—ចប់—

## ឧបសម្ពន្ធ

# ប្រវត្តិសង្គមមនុស្ស

ផែនដីយើងកាលពីដើម ជាដុំភ្លើងវិលជានិច្ច ៗ យូរមកដោយការប្រែប្រួលនៃធាតុធម្មជាតិផ្សេង ៗ ដុំភ្លើងនោះបានត្រជាក់ ៗ រុក្ខជាតិសត្វតូចធំ ចាប់ផ្ដើមមានជីវិតឡើង ៗ តមកទៀត មនុស្សក៏បានកើតឡើងដែរ ៗ តាំងពីមានមនុស្សមក គេឃើញមានសង្គមមនុស្សវិវត្តន៍ពីទាបទៅខ្ពស់ជាលំដាប់ សង្គមសមូហភាពបុព្វកាល, ទាសភាព, សក្តិភូមិ, ទុននិយម សង្គមនិយម ៗ

១–សង្គមសមូហភាពបុព្វកាល–ដើមឡើយមនុស្សរស់ដោយសារធម្មជាតិ ដើរបេះផ្លែឈើចិញ្ចឹមជីវិត ហើយទៅណាមកណាទៅទាំងហ្វូង ៗ ។ ក្នុងការតស៊ូទល់នឹងធម្មជាតិ

សម័យនោះ មនុស្សប្រើសាមគ្គីស្រឡាញ់គ្នាជាពន់ពេក គំនិតបោកជិះជាន់គ្នាពុំទាន់កើតមានឡើយ ។

២- សង្គមទាសភាព – ក្នុងការបង្កើនផល (ការងារ)

មនុស្សបានរកឃើញមធ្យោបាយជាច្រើន ហើយបានចេះគាប់គាស់ចំការចិញ្ចឹមសត្វត្រួតត្រាធម្មជាតិបានខ្លះ ជាហេតុផ្ដើមការរកស៊ីរស់នៅប្លែកៗគ្នា មានខ្លះខ្លាំងពូកែ ជិះកំហែងអ្នកទន់ខ្សោយឲ្យរកប្រយោជន៍ឲ្យខ្លួន ។ ក្នុងសង្គមនេះគេឃើញ :

ក) ការបង្កើនផលិតកម្ម: បេះចិញ្ចឹមសត្វគាប់គាស់ទីដីកម្លាំងមនុស្សផ្ទាល់ ។ ផលិតកម្មនៅខ្សោយ ។

ខ) ការចែកផលិតកម្ម: (មនុស្សនិងមនុស្ស)ឬបែងចែកផលិតផលមិនបានស្មើគ្នាទេ ។ ខ្ញុំកំដរឬទាសាធ្វើការចិញ្ចឹមចៅហ្វាយម្ចាស់ ។ មានការជិះជាន់គ្នា ការទំនាស់វណ្ណៈរវាងខ្ញុំកំដរនឹងចៅហ្វាយម្ចាស់ ។

## ៣-សង្គមសក្តិភូមិ

ក) ការបង្កើនផលិតកម្ម: មនុស្សរាហកម្មគ្រួសារ

ត្បាញក្រអស់នឹងធនក្តីល ៖ គោស បានចិញ្ចឹមជាន់សម័យភាស

កាត ។

ខ) ការបាត់បង់ផលិតកម្ម: ស្តេចត្រាញ់

(សក្តិភូមិ) បង្ខំឲ្យអ្នកភាគសកិការ ធ្វើការ ធ្វើស្រែឲ្យខ្លួន ។ មាន

ការទំនាស់វណ្ណៈទៀត រវាងសក្តិភូមិនិងអ្នកភារ ។

## ៤-សង្គមមូលធនិយម

ក) ការបង្កើនផលិតកម្ម: មនុស្សរាហកម្មធំៗ

រហូតក្រុមមនុស្សប្រើកម្លាំងម៉ាស៊ីនត្រួតធម្មជាតិ;

ខ) ការបាត់បង់ផលិតកម្ម: នាយទុនប្រ

មូលយកផលតែម្នាក់ឯង ជះជាន់កម្មករឲ្យវេទនា ។

មានការទំនាស់វណ្ណៈរវាងនាយទុននិងកម្មករ ។

# ៥- សង្គមនិយម

ក) ការបង្កើតផលិតកម្ម: ឧស្សាហកម្មធំៗ ពេនចក្រ មនុស្សបង្កើតតិកនិកថ្មីៗ ត្រួតត្រាធម្មជាតិ ។

ខ) ការណាត់ចែងផលិតកម្ម: បែងចែកឲ្យមកអ្នកធ្វើការទាំងអស់គ្នា ផ្អែកទៅលើគោលការណ៍ «ម្នាក់ៗត្រូវឲ្យទៅសង្គមតាមសមត្ថភាពរៀងៗខ្លួន ហើយសង្គមសងមកវិញ តាមការងាររួចតាមសេចក្តីត្រូវការនៃម្នាក់ៗ» ។

ការវិវត្តន៍សង្គមពីទាបទៅខ្ពស់នោះ បានជួបប្រទះការប្លាំងប្លាក់ជាច្រើន ជៀសវាងការបដិវត្តន៍មិនបាន ។

ការបដិវត្តន៍ ឆ្នាំ ១៧៨៩ រំលាយរបបសក្តិភូមិនៅស្រុកបារាំង ។ល។

# បញ្ជីរឿង

ទំព័រ


អារម្ភកថា - - - - - - - - - - - - - ក

ប្រវត្តិកំណើតអក្សរសាស្ត្រ - - - - - - - - ១

អក្សរសាស្ត្រខ្មែរ - - - - - - - - - - - ៥

អក្សរសាស្ត្រសម័យអង្គរ - - - - - - - - - ១៧

អក្សរសាស្ត្រក្រោយសម័យអង្គរ ឆ្លងតាមលង្វែក មកឧត្តុង្គរជ្ឈកាលព្រះអង្គឌួង - - - - - - ២២

ក) របៀបសិក្សា - - - - - - - - - - - ២៣

ខ) គ្រូអាចារ្យ - - - - - - - - - - - ២៤

គ) កម្មវិធី - - - - - - - - - - - - - ២៥

អក្សរសាស្ត្រចែកជាបង្គោមធំពីរ - - - - - - ២៨

អក្សរសាស្ត្របដិកិរិយា - - - - - - - - ២៩

ក) រឿងសាសនា - - - - - - - - - - - ៣០

ទំព័រ

ខ)- ច្បាប់ក្រមប្រុស ស្រី - - - - - - - ៣០

គ)- ច្បាប់កឹងកៃត្រិ - - - - - - - -៣៦

ឃ)- ស្ត្រីល្បើ - - - - - - - - ៣៣

ង)- រឿងទាវ-ឯក - - - - - - - - ៣៧

រឿងទាវ-ឯករបស់លោកប៊ុលសេនា នូ-កន - - - ៤៤

អក្សរសាស្ត្រប្រជាជន - - - - - - ៥០

ក) រឿងព្រេងប្រឆាំងទៅនឹងការបន់ស្រន់ថាមាន

អ្នកតា - - - - - - - - - - - ៥២

ខ) រឿងព្រេងប្រឆាំងនឹងមន្តអាគម - - - - - ៥៤

គ) រឿងព្រេងប្រឆាំងរបបសង្គមផាប់ខុតុកក្មេក - - ៥៥

ឃ) រឿងអាឡេវ - - - - - - - - - ៥៦

ង) រឿងធ្មេញជ័យ - - - - - - - - ៥៩

ច) រឿងសុភាទន្សាយ - - - - - - - - ៦៣

ទំព័រ

អក្សរសាស្ត្រខ្មែរក្រោមនឹមដែកអាណានិគមនិយម
ប៉ារាំង ១៩៤៥ . . . . . . . ៧០

១) បង្កើតសាលាបាលី . . . . . . . . ៧២

២) ក្តាប់បណ្ឌិតអក្សរសាស្ត្រខ្មែរ . . . . . . [illegible]

ទៅក្នុងរបបអាណានិគមនិយមអក្សរសាស្ត្រខ្មែរ
សាបសូន្យ . . . . . . . . . . . . . ៧៦

គតិលោក . . . . . . . . . . . . . . ៧៧

ច្បាប់ក្រមង៉ុយ . . . . . . . . . . . . ៨០

អក្សរសាស្ត្រខ្មែរក្រោយសង្គ្រាមលោកលើកទីពីរ ៨

អក្សរសាស្ត្រខ្មែរសម័យឯករាជ្យប្រជាធិបតេយ្យ ៩០

—០០០—

ឧបសម្ព័ន្ធ

ប្រវត្តិសង្គមមនុស្ស . . . . . . . . ៩៥

[illegible]
BAYON
MARKET & GIFT SHOP
A Khmer Arts Center
1161 E. 10th St., Long Beach, CA 90813
Tel. (213) 599-3120 • Fax. (213) 599-2337

$ 1000